# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៤ ខែកុម្ភៈ លេខ ២

ព.ស. ២៤៩៤ — គ.ស. ១៩៥២

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ


សារាណិយធម្មកថា (តចប់) .......... ព្រះមហា កែ - អៀន ........ ៨៣

ពន្លឺអាស៊ីទ្វីប (តមក) ............ លោកភ័យ - ប៊ុក .......... ៩១

សុភោជាយកថា .................. ព្រះអាចារ្យ ទូច - ឡេង ..... ៩៧


ផ្នែកអក្សរសាស្ត្រ


រឿងគ្រូសាញ់អ្នកខ្លាំងពូកែ (តចប់) ...... សាស្ត្រាចារ្យផេង - ជ្រីវ ..... ១០៩

ការបណ្ដុះនិស្ស័យ (តមក) ........ ព្រះមហាឧត្ដមវិជ្ជា ប៊ុង - ប៉ម ... ១១៩

រឿងសាមកុក (តមក) ............ ឧកញ៉ា ទូ - កន .......... ១២៧

រឿងអារក្សថ្វេងរឿងម្ដេប្រាំ (តមក) .... លោកសាង - សាភ៌ត ........ ១៣៥

រឿងស្នេហាជាតិ .................. លោក គង់ - លឹម ......... ១៤៣


កំណត់នឹងប្រវត្តិការណ៍


ពិធីបុណ្យដ៏ឧឡារិកនៅវត្តដើមអម្ពិល ខែត្រ
បោ៉ណាវ (យៀកណាម) (តចប់) ..... ព្រះមហា ឈិត - កំលិន .... ១៥៤



មួយឆ្នាំមាន ១២ សៀវភៅ — ដំថ្លៃជាវ ១៨៣រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES


### PARTIE RELIGIEUSE

| | | Pages |
|---|---|---|
| Saraniyadhammakathâ (Suite et fin) | *Vén. Ker-Œurn* | 83 |
| La lumière de l'Asie (suite)..... | *M. RAY-BUC* | 91 |
| Sukhopâyakathâ ............... | *Vén. TOUCH-LENG* | 97 |

### PARTIE LITTERAIRE

| | | |
|---|---|---|
| Créçanau, le vaillant (Conte romain) (suite et fin).. ...... | *M. Phéng Chrieu* | 109 |
| Education morale (suite)........ | *Vén. PŒUNG-PAM* | 119 |
| Histoire de SAMKOK (suite) .... | *Oknha NOU-KAN* | 127 |
| Les vingt cinq récits du Mauvais Génie (suite) ................ | *M SAN-SAVAT* | 135 |
| L'Amour de la partie (pièces de Théâtre).................. | *M Kong-Lim* | 143 |

### NOTES ET CHRONIQUES

| | | |
|---|---|---|
| Cérémonies religieuses de Vatt Dœum Ampil, à Baclieu (Sud-Vietnam)... ... ........... | *Vénérable Chhit-Kcmlin* | 154 |


Prix d'abonnement annuel (12 numéros: ) 18$00

# សារាណីយធម្មកថា

## ព្រះមហា កែ-អឿន (វីរយប្បញ្ញោ)

វត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប រៀបរៀង

ឃុនសុវត្ថិវេទី យូរ-អ៊ុន អ្នកពិនិត្យកែ

(តចប់)

---

ន័យ ១ ទៀត បុគ្គលប្រព្រឹត្តខ្លួនឲ្យមានកាយវាចារៀបរយល្អ បើនឹងធ្វើអ្វី ក៏មិនឲ្យអ្នកដទៃលំបាកដោយឥតហេតុ បើនឹងពោលអ្វីពោលតែវាចាពីរោះ គួរទុកក្នុងចិត្ត, តែងមានសេចក្ដីឃើញត្រូវតាមហេតុតាមផល, កាលបើគិតអ្វីៗ ក៏សុទ្ធតែជាហេតុឲ្យសម្រេចផលល្អ ជាប្រយោជន៍ដល់ខ្លួននឹងអ្នកដទៃ, អ្នកដែលប្រព្រឹត្តដូច្នេះ អាស្រ័យគុណគឺសេចក្ដីល្អរបស់ខ្លួន តែងជាទីរីករាយនៃប្រជុំជន នាំគ្នាសង្គ្រោះចិត្តគ្នានឹងគ្នា ៗ ព្រោះហេតុដូច្នោះហើយ អ្នកៗមានបំណងចង់បានសេចក្ដីសុខដល់ពួកក្រុម សង្គម គណៈ ប៉ងនឹងចងមេត្រីនឹងអ្នកដទៃ មិនប្រាថ្នាចំពោះប្រយោជន៍ខ្លួនតែម្យ៉ាង គប្បីបំពេញសារាណីយធម៌ ៦ យ៉ាងនេះ ឲ្យបរិបូណ៌ក្នុងសន្តានដូចអធិប្បាយមកនេះ ៗ

បន្ទាប់អំពីនេះ នឹងសំដែងបំភ្លឺដល់គ្រហស្ថជាសេចក្ដីល្មមសមគួរ ៗ ធម៌ទាំង ៦ យ៉ាងនេះ គ្រហស្ថក៏ត្រូវប្រព្រឹត្តប្រតិបត្តិបានដូចគ្នា ៗ ឯកិច្ចការខាងគ្រហស្ថនេះ មានក្រុម ឬ គណៈសង្គមច្រើនជាអនេកប្បការ

ណាស់ រាប់ចាប់តាំងអំពីព្រះរាជាជាម្ចាស់ផែនដីនិងអ្នករាជការជាលំដាប់ៗ ក្នុងព្រះរាជអាណាចក្រទាំងមូល រហូតទៅដល់ប្រជារាស្ត្រទាំងអស់ សុទ្ធតែមានក្រុម សង្គម គណៈគ្រប់ៗមុខនាទី ។ ក្នុងក្រុម សង្គម គណៈនីមួយៗ សុទ្ធតែមានមេបញ្ជាការ ជានាយកលើក្រុមសង្គមគណៈនោះៗ មានការត្រួតត្រាបញ្ជាការទៅលើអ្នកនៅក្រោមបង្គាប់របស់ខ្លួនៗ, លោកជានាយកទាំងនោះ ដែលជាអ្នកបញ្ជាការត្រួតត្រាលើគេ ត្រូវជាអ្នកប្រកបដោយធម៌ជាគុណសម្បត្តិ សម្រាប់ខ្លួន ៦ ប្រការគឺ :-

១ — ខមា – ជាអ្នកមានសេចក្តីអត់ធន់ ចំពោះអនិដ្ឋារម្មណ៍គឺ អារម្មណ៍ដែលនាំឲ្យកំហឹងកើតឡើងផ្សេងៗ ។

២ — ជាគរិយៈ – ជាអ្នកមានសេចក្តីភ្ញាក់រលឹករឿយៗ ចំពោះករណីយកិច្ចគ្រប់យ៉ាង ។

៣ — ឧដ្ឋានៈ – ជាអ្នកមានសេចក្តីឧស្សាហ៍ព្យាយាម ក្នុងករណីយកិច្ចដែលត្រូវធ្វើ មិនរួញរា ។

៤ — សំវិភាគៈ – មានការចែករំលែកលាភដែលបានមក ដល់អ្នកដែលនៅក្រោមបង្គាប់ ជាសាធារណ៍ តាមមានបាន ។

៥ — ទយា – ជាអ្នកមានសេចក្តីអាណិតអាសូរទូទៅ ដល់អ្នកនៅក្រោមបញ្ជាការ ។

៦. ឥក្ខនា – មានការពិនិត្យត្រួតត្រា ពិចារណាមើលហេតុផ្សេងៗ ដោយម៉ត់ចត់ ។

បុគ្គលជានាយកលើគេ បើប្រកបដោយធម៌ជាគុណសម្បត្តិ ទាំង ៦ យ៉ាងនេះហើយទើបមានសម្ភាពស័ក្តិសមជានាយកបាន ។

បុគ្គលដែលនៅក្រោមបង្គាប់បញ្ជាការ របស់នាយកនោះៗ ត្រូវស្តាប់បង្គាប់គោរពកោតខ្លាចលោកជានាយករបស់ខ្លួន មិនត្រូវព្រហើនកោងកាចតាមអំណាចចិត្តអន្ធពាលឡើយ ។

មួយទៀតបុគ្គលជាគ្រហស្ថតាមតែក្រុម សង្គម គណៈណាក៏ដោយដែលនឹងនៅដោយសេចក្តីព្រមព្រៀងគ្នា ជាទីស្រឡាញ់គោរពរាប់អានគ្នា បានសេចក្តីសុខ សេចក្តីចម្រើនអស់កាលជាយូរអង្វែងទៅបាន ក៏ដោយអាស្រ័យសារាណីយធម៌ទាំង ៦ ប្រការដែរ ។ ដូច្នេះនឹងលើកយកសារាណីយធម៌នោះមកអធិប្បាយតាមសមគួរតទៅទៀតគឺ :

១. អំពើកាយប្រកបដោយមេត្តា — នោះបានដល់ការខ្នះខ្នែងខ្វល់ខ្វាយជួយគ្នា ដូចជាពួកក្រុមមនុស្សណាមួយ មានកិច្ចធុរៈ កើតឡើងដែលជាកិច្ចត្រូវធ្វើដោយកាយ ពួកមនុស្សដែលនៅក្នុងក្រុមនោះក៏ជួយខ្នះខ្នែងខ្វល់ខ្វាយធ្វើកិច្ចនោះ ឲ្យសម្រេចទៅតាមកំឡាំងរៀងខ្លួន ដូចជាជួបប្រទះមនុស្សឈឺគ្រុនយ៉ាំងធ្ងន់ យើងមានសេចក្តីករុណាបន្តក់ថ្នាំ ជួយឈឺឆ្អាលរកគ្រូពេទ្យមករក្សាថែទាំមើលជម្ងឺ, ឬមានភ្លើងឆេះផ្ទះ

អ្នកដទៃយើងទៅជួយលត់ ជួយជញ្ជូនយកទ្រព្យរបស់គេ ឲ្យផុតអំពីអន្តរាយ, ទូកលិចក្មេងលង់ទឹក យើងហែលទៅជួយឲ្យរួចផុតពីសេចក្តីអន្តរាយ ដោយហោចទៅ សូម្បីគ្រាន់តែឃើញគេឈឺគ្រុនធ្ងន់ យើងទៅសួរទៅមើលតែប៉ុណ្ណោះក៏គង់ឃើញថា យើងមានសេចក្តីអាណិតអាសូរករុណា, កាលបើយើងមានកិច្ចធុរៈ ឬអន្តរាយកើតដូច្នោះវិញ អ្នកដទៃគេក៏គង់មកជួយកិច្ចធុរៈយើងវិញដែរ, នេះហើយហៅថាចងមិត្តមេត្រីនឹងគ្នាទៅវិញទៅមក ។

២. អំពើវាចាប្រកបដោយមេត្តា— នោះបានដល់ការជួយនិយាយដាស់តឿនក្រើនរំលឹកអ្នកណាមួយ ដែលធ្វើខុសអំពីបញ្ញត្តិច្បាប់របស់ស្រុក-នគរជាដើម, មានសេចក្តីករុណាជួយហាមប្រាមឃាត់មិនឲ្យធ្វើ ឬក៏ជួយប្រៀនប្រដៅឲ្យប្រព្រឹត្តក្នុងផ្លូវល្អប្រពៃ ឲ្យប្រកបរបស់ដែលមានប្រយោជន៍ដោយមេត្តាចិត្ត ។

ម្យ៉ាងទៀត ការសំដែងមេត្តាដោយវាចានោះ អ្នកប្រាជ្ញលោកសំដែងទុកថា សូម្បីតែនិយាយសាកសួរសុខទុកដល់គ្នានឹងគ្នា ក៏រាប់ថាជាមនុស្សមានចិត្តល្អ ។ ឯវាចាដែលពីរោះទន់ភ្លន់គួរទុកក្នុងចិត្តនេះ ជាវាចាដែលនិយាយងាយស្រួលជាងវាចាត្រគោះបោះបោក, វាចាត្រគោះបោះបោកនោះជាវាចាពិបាកនិយាយ ព្រោះត្រូវប្រយ័ត្នក្រែងគេក្រោធខឹងឬមិនពេញចិត្ត ។

ឯពាក្យដែលថាទៅគេ រមែងទទួលផលជា ២ យ៉ាងគឺ ពាក្យអាក្រក់ រមែងឲ្យផលអាក្រក់, ពាក្យពីរោះទន់ភ្លន់រមែងឲ្យផលល្អ អាចឲ្យបានទទួលសេចក្ដីរាប់អានពីសំណាក់គ្នាជាដើម ទាំងអាចមានចិត្តអាណិតអាសូរដល់គ្នាផង ។

៣- អំពើចិត្តប្រកបដោយមេត្តា — នោះបានដល់មេត្តាចិត្តប្រាថ្នាមិនចង់ពៀរដល់គ្នានឹងគ្នា សូម្បីមិនបានជួយខ្វះខ្វែងកង់កិច្ចធុរៈដោយកាយពាក្យទេ តែចិត្តប៉ុណ្ណោះហើយ អាការកាយនឹងពាក្យដែលប្រាកដចេញមកខាងក្រៅនោះ ក៏គង់នឹងត្រូវចិត្តអ្នកដទៃ ។ មនុស្សយើងធ្វើឬគិតអាក្រក់ល្អក៏ព្រោះចិត្ត បើចំពោះតែកាយដូចរូបតុក្កតា, ឯចិត្តដូចមនុស្សទាញកាយ នឹងពាក្យប្រព្រឹត្តទៅយ៉ាងណា ក៏ប្រព្រឹត្តទៅតាមចិត្តនោះ ។

សូមចាំកុំភ្លេចថា: យើងមេត្តាគេៗមេត្តាយើង, យើងធ្វើឲ្យគេប៉ុណ្ណា គេធ្វើឲ្យយើងប៉ុណ្ណោះវិញ ។ ការសំដែងមេត្តាចិត្តនេះ កុំថាតែមនុស្ស សូម្បីសត្វតិរច្ឆានទាំងឡាយ មានឆ្កែនឹងឆ្មាជាដើម កាលបើមនុស្សស្រឡាញ់ទៅហើយ វាសំដែងអាការញើករញ៉ាក់បក់កន្ទុយមករកយើង, បង្ហាញឲ្យឃើញថាវាមានសេចក្ដីស្រឡាញ់យើង ។

៤ — ការចែករំលែកលាភដល់គ្នីគ្នា — នោះគឺកាលបើបានបច្ច័យឬវត្ថុរបស់ណាមួយដោយធម៌ហើយ អាចចែករំលែកលាភនោះឲ្យ

ដល់ពួកក្រុមសង្គម ឬដល់កូនប្រពន្ធនៅក្នុងទីកន្លែង ផ្ទះសំបែងរបស់ខ្លួន ឬដល់ពួកជនដែលនៅជិតខាងបរិភោគប្រើប្រាស់ទោះតិច-ច្រើន តាមមានតាមបាន ។

៥ — រក្សាសីលបរិយាឱ្យមានសណ្ដាប់ធ្នាប់ល្អ — បានដល់ការមិនធ្វើឱ្យជាទីរង្កៀសរបស់អ្នកដទៃពោលគឺការធ្វើ កិរិយាបរិយា សណ្ដាប់ធ្នាប់នៃកាយវាចាស្មើគ្នា ដែលហៅថាសីល ។ សីលនេះអាចនាំអ្នកដទៃសូម្បីផ្សេងជាតិផ្សេងភាសា ដូចខ្មែរ, ភូមា, មន, លាវជាដើម ឱ្យមានសេចក្ដីប្រព្រឹត្តត្រូវគ្នាជាធុងមួយបាន ព្រោះកាន់ព្រះពុទ្ធសាសនាដូចគ្នា ។ សីលនេះលោកប្រៀបដូចជាអម្បោះ សម្រាប់ក្រងផ្កាឈើ មានពណ៌ផ្សេងគ្នាយកមកបញ្ចូលជារបៀបមួយ អាចក្រឡេកមើលទៅឃើញល្អគួរជាប់ភ្នែកជាប់ចិត្ត ។ បើអ្នកកាន់សាសនាត្រូវគ្នាហើយ តែប្រព្រឹត្តផ្សេងអំពីពួករបស់ខ្លួន, ក៏រមែងជាទីរង្កៀសរបស់អ្នករួមសាសនាជាមួយគ្នា ជាហេតុឱ្យបែកសាមគ្គីគ្នា ។

៦ — ធ្វើសេចក្ដីឃើញឱ្យត្រឹមត្រូវ — បានដល់សេចក្ដីយល់ឃើញត្រូវគ្នា គឺបុគ្គលដែលនឹងគប់គ្រងគ្នា ជាគណៈ សង្គមបានព្រោះអាស្រ័យសេចក្ដីរួមគ្នាទើបគប់គ្រងគ្នាបាន, បើមានសេចក្ដីឃើញម្នាក់ផ្លូវមួយ យ៉ាងគាមិនស្របមតិគ្នា ទោះបីមានសេចក្ដីប្រព្រឹត្តល្អក៏ដោយ ក៏គង់សមាគមនឹងគ្នាទៅមិនបានរហូតឡើយ, ព្រោះខុសខាតសេចក្ដីយល់

មិនព្រមព្រៀងគ្នា រមែងជាហេតុឲ្យកើតទាស់ទែងខ្វែងគំនិតគ្នា មិនអាចធ្វើករណីយកិច្ចដែលត្រូវអាស្រ័យប្រើគ្នានោះឲ្យសម្រេចប្រយោជន៍ទៅបានទេ, ដូចជាអូសឈើឬសែងសសរជាដើម សូម្បីតាំងចិត្តឲ្យឈើនោះទៅដល់កន្លែងដែលខ្លួនប៉ងប្រាថ្នាជាមួយគ្នានោះ តែគំនិតមិនស្របគ្នា ព្រោះមួយឃើញថាធ្វើក្នុងវេលាព្រឹក, មួយឃើញថាធ្វើក្នុងវេលារសៀល, ពុំនោះសោតដូចកិច្ចការប្រជុំធំៗ មានការប្រជុំរបស់រដ្ឋាភិបាលក្នុងនគរនីមួយៗ បើម្ខាងមានសេចក្តីយល់ឃើញផ្លូវមួយ ម្ខាងគំនិតគ្នាមិនស្របមតិគ្នា ក៏គង់ការប្រជុំនោះមិនបានសម្រេចប្រយោជន៍ ។ ហេតុដូច្នោះការឃើញរួមគ្នាក្នុងការដែលត្រឹមត្រូវដែលសម្រេចប្រយោជន៍, ជាគុណជាតិសំខាន់យ៉ាងទីបំផុតក្នុងករណីយកិច្ចគ្រប់យ៉ាង ។

គណៈសង្គមណា ប្រកបដោយសារាណិយធម៌ ៦ ប្រការនេះ គណៈសង្គមនោះ គួរជាទីស្រឡាញ់ គោរពរាប់អានរបស់មហាជនទាំងពួង នាំឲ្យមានសេចក្តីសង្គ្រោះដល់គ្នានឹងគ្នា មានសេចក្តីព្រមព្រៀងជាមួយគ្នានឹងនាំឲ្យមានសេចក្តីសុខ សេចក្តីចម្រើនអស់កាលជាយូរអង្វែង មិនមានសេចក្តីសាបសូន្យឡើយ ។

សំដែងមកអំពីសារាណិយធម្មកថា ក៏ល្មមសមគួរដល់វេលា សូមសន្មតថាចប់តែប៉ុណ្ណេះ ។

ទុក្ខប្បត្តា ច និទ្ទុក្ខា      ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា   ហោន្តុ សព្វេបិ បាណិនោ ។

*សព្វសត្វទាំងឡាយ ដែលដល់ហើយនូវទុក្ខ សូមឲ្យជាសត្វបាត់ទុក្ខទៅ! ដែលដល់ហើយនូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ! ដែលដល់ហើយនូវសេចក្ដីសោក សូមឲ្យបាត់សេចក្ដីសោកទៅ ! ។*

រតនត្តយតេជេន      កម្ពោជរដ្ឋវាសិនោ
វុឌ្ឍឹ វិរុឡ្ហឹ បប្បោន្តុ    សន្តិភាវញ្ច នាញ្ញថា ។

*ដោយតេជះនៃព្រះរតនត្រ័យ (មានពុទ្ធរតនៈជាដើម) សូមឲ្យប្រជាជនទាំងឡាយ អ្នកកើតនៅក្នុងកម្ពុជរដ្ឋ ដល់នូវការៈលូតលាស់ចម្រើន និងសន្តិភាព កុំបីឃ្លៀងឃ្លាត ក្លាយទៅជាប្រការដទៃឡើយ ។*

ចប់

**ស្លាប់ព្រោះជួយជាតិប្រសើរបំផុត**

អ្នកណាកើតមក ហើយស្លាប់ទៅវិញ ដោយឥតបានទុកនាមនិងគោត្រ ឲ្យប្រជាជនដឹងផងសោះ អ្នកនោះទុកដូចមិនធ្លាប់មានជីវិតរស់នៅក្នុងលោកឡើយ ។  *យ. អ.*

# ពន្លឺអាស៊ីទ្វីប

## វគ្គទី ៨

**La Lumière de l'Asie**

*លោក ស៊ីរ-អេតវិន អារណូលត៍ តែង*

លោកប៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

*ព្រះមហាក្សត្រិយ៍, ព្រះសម្មាសម្ពុទ្ធ, ព្រះនាងយសោធរា និងប្រជារាស្ត្របាននាំគ្នាទៅដល់ពីមុខព្រះបរមរាជវាំង ព្រះបាទសុទ្ធោទនៈ ដែលទ្រង់មានព្រះនលាដ៍ឥតមានជ្រួញជ្រីវអ្វីឡើយ ទ្រង់បានសោយជាសុខនូវព្រះឱជារស នៃឱវាទព្រះសម្មាសម្ពុទ្ធ ដែលទ្រង់កាន់នូវអម្បែងសូមទាន, ហើយក្នុងពេលនោះ អាភាស្វាងសែងចេញចាកព្រះនេត្រា នៃព្រះនាងយសោធរាក៏យល់ជាក់ច្បាស់, ទ្រង់បាត់សោយសោក; ហើយក្នុងយប់នោះ ព្រះវរបិតានិងព្រះនាងយសោធរា ទ្រង់ក៏បានយាងទៅកាន់ផ្លូវសន្តិភាពដ៏ប្រសើរជាអវសាន ។*

## វគ្គទី ៨

*មានវាលស្មៅមួយនៅតាមមាត់ជ្រោះកុហានៈនិងនគរ, បើចង់ទៅកាន់វាលនេះ ត្រូវតែធ្វើដំណើរប្រាំថ្ងៃដោយរទេះគោ តម្រង់ទៅខាងទិសឦសាននៃទីក្រុងប៉ោណារេស ក្រុងដែលមានវត្តច្រើនជាងគេ ៗ*

ក្នុងហិមាល័យ មានកំពូលស្រួច មានទឹកកកពាសពេញស្ថិតនៅទីនោះ មានបុប្ផាជាច្រើន និងគុម្ពោតព្រៃដែលមានទឹកស្អិតហូរស្រោចធ្វើឲ្យធម្មជាតិទាំងនោះមានពណ៌ខៀវស្រស់ល្អ, ក្នុងនោះមានខ្នងទេរស្រួល ហើយមានម្លប់ត្រសុំសាខា ផ្សាយនូវគន្ធពិដោរក្រអូបឈ្ងុយឈ្ងប់ត្រជាក់ចេញតាមរំយោផាត់ក្លិនសន្តិភាព ផ្សព្វផ្សាយពាសពេញទីកន្លែងនោះគួរជាទីគោរព វាយោក្នុងសាយណ្ហសម័យបក់បោកមកលើគុម្ពោតព្រៃដែលមានរុក្ខជាតិដុះក្រាស់ហើយមានដុំថ្មក្រហមធ្លាក់ជាក្បាច់ ប្រែះក្រហែងដោយឫសនិងមែកព្រៃ ដែលធ្លាក់សំយុងមកបាក់ធ្លាយកាន់ប្រថពី ហើយមានស្មៅនិងស្លឹកឈើរុំព័ទ្ធជុំជិត ៗ មានសត្វពស់វារលូនដោយស្ងប់ស្ងៀមចេញពីប្រហោងរុក្ខជាតិទាំងនោះ ដែលមានជ័រអាចម៍ល័ក្ខហូរចេញកករក្រៀមក្រពឹតពីប្រហោងឈើសែដ (cèdre) របេះជ្រុះផុយធ្លាក់, ហើយពេនខ្លួនរាបញ្ចេញស្រកាមានគំនូររូបរាងនៅលើក្រោលថ្មកែវមានពណ៌ក្ដីដូចថ្ងៃ, បង្គួយភាពរហ័សរត់ទៅលើក្រោលឥដ្ឋ មានគំនូរពណ៌ដែលព្រះមហាក្សត្រិទ្រង់ត្រាប់ចុះឡើង, សត្វកញ្ជ្រោងមានសម្បុរប្រផេះដេកសុខស្រួលនៅក្រោមព្រះបល្ល័ង្កដែលបាក់បែក, ក្រៅពីនោះមានតែកំពូលភ្នំ, ស្ទឹង, វាលស្មៅ មានបង្កើះពោតនិងរៈយាបក់រំភើយ ៗ ដែលមានស្ថានភាពមិនប្រែប្រួល ៗ សល់ខាងអំពីនេះ វត្ថុទាំងឡាយដូចជាទស្សនិយដ្ឋាននៃជីវភាព ក៏រលត់រលាយសូន្យឈឹងដោយហេតុថានៅទី

នោះឯងដែលស្ថាបនានូវព្រះរាជធានីនៃព្រះបាទសុទ្ធោទនៈ ទីងក៏តូចៗ ដែលពេលសាយណ្ហសម័យមានមេឃខៀវប្រក្រហមដូចមាស ព្រះសម្មា-សម្ពុទ្ធទ្រង់គង់ដើម្បីសំដែងធម៌ប្រោសសត្វនិករ ។

អ្នកអាចអាននូវគម្ពីរពិសិដ្ឋហើយយល់បានថានៅទីគួរពិតពិលរមិលមើលនេះ ពីដើមជាឧទ្យានមានផ្លូវដើរចិញ្ចើមបោត, ប្រកបត្រពាំងបឹង, កម្រាលមាត់ថ្នល់មានផ្កាកុលាប ហើយមានប្រាសាទដំណាក់មានក្លោងទ្វារដ៏វិចិត្រ ព្រះបរមគ្រូជាម្ចាស់នៃយើងទ្រង់គង់ចំពោះមុខប្រជាជនសំដែងការវគាត ដែលរង់ចាំស្ដាប់ដោយសេចក្ដីស្ងប់ស្ងៀមនូវព្រះឱវាទដែលចេញហូរពីព្រះឱស្ឋ ដើម្បីនឹងរចនាសត្វនិករឲ្យមានប្រាជ្ញាភ្លឺស្វាងរុងរឿងដែលអប់រំឲ្យទ្វីបអាស៊ីទាំងមូលមានសភាពសុគន្ធ; ហើយក្នុងពេលនោះមានសត្វនិករចំនួនបួនពាន់សែននាក់ ដែលក្រាបនុជាសេនូវព្រះសទ្ធម្មទេសនារបស់ព្រះអង្គ នឹងជាដូចម្ដេចទៅ?

ព្រះសម្ពុទ្ធទ្រង់គង់ខាងស្ដាំព្រះមហាក្សត្រ ហើយព្រះអង្គម្ចាស់សាក្យៈ អានន្ទ, ទេវទត្តនឹងមន្ត្រីក្នុងព្រះបរមរាជវាំង ព្រមទាំងព្រះរាជវង្សានុវង្សគង់ជុំវិញទ្រង់ ។

ពីខាងក្រោយព្រះអង្គ ព្រះសារីបុត្តនឹងព្រះមោគ្គល្លាន អរិយសាវករបស់ទ្រង់ ក្នុងចំណោមព្រះកុលបុត្តស្បង់លឿងទាំងអស់គង់ជាកិត្តិយសក្នុងក្រមដ៏ប្រសើរនោះ ។ នៅចំប្រឡោះព្រះជនកព្រះអង្គ, ព្រះរាហុល

ទ្រង់ព្រះសិតការណ៍ (ហេតុនៃការញញឹម) ហើយទ្រង់ផ្ទៀងព្រះនេត្រ តម្រង់ចំព្រះភ័ក្ត្រគួរជាទីជ្រះថ្លានៃព្រះវរបិតា, ហើយនៅខាងព្រះបាទាទ្រង់ នាងយសោធរាបាកបេញពីកិលេសហើយ មានបំណងទៅកាន់ព្រហ្មវិហារដ៏ឧត្តម ដែលផុតពីអាហារពោលគឺអាយតនៈទាំងខាងក្នុងខាងក្រៅ, ជីវភាពដែលគ្មានជរា ហើយដល់អស់ព្រះជន្មាយុជាបរិយោសានដែលនឹងមានមកក្នុងពេលខាងមុខនេះ, ដល់សេចក្ដីស្លាប់ៗ បាត់បង់លែងមានតទៅទៀត, ក្នុងកាលដែលព្រះសិទ្ធត្ថនឹងព្រះនាងទទួលនូវជោគជ័យដ៏ប្រសើរ ។ ព្រះនាងបានយកម្រាមព្រះហស្តទៅប៉ះនឹងព្រះហស្តព្រះសម្ពុទ្ធ ហើយយកជាយព្រះពស្ត្រមានពណ៌សដូចប្រាក់ទៅរុំព័ទ្ធនឹងស្បង់លឿងព្រះរាជស្វាមី ដែលជាបុគ្គលជាទីពេញព្រះរាជហឫទ័យនៃព្រះនាងជាងសត្វលោកក្នុងត្រៃយភព ពេញចិត្តចង់ស្លាប់ព្រះពុទ្ធោវាទទៅទៀត ។ ខ្ញុំមិនអាចពណ៌នាអំពីឧត្តមគតិ នៃព្រះឱវាទដ៏វិសេសវិសាលដែលហូរពីរមព្រះឱស្ឋនៃព្រះសម្មាសម្ពុទ្ធ ។

ខ្ញុំជាអ្នកនិពន្ធមកដល់ក្រោយគេបង្អស់ ដែលជាអ្នកពេញចិត្តខាងព្រះសម្មាសម្ពុទ្ធ ជាព្រះបរមគ្រូដែលមានព្រះទ័យអាណិតអាសូរដល់មនុស្សសត្វក្នុងភព ហើយជាអ្នកថ្លែងរឿងរ៉ាវនេះ ដោយយល់ឃើញថាព្រះអង្គជាព្រះសព្វញ្ញូពុទ្ធ តែខ្ញុំពុំមានប្រាជ្ញាគ្រប់គ្រាន់ ដើម្បីនឹងពណ៌នាឲ្យច្បាស់លាស់ដោយមិនបាច់អានសៀវភៅគម្ពីរ ដែលកាលបាន

ធ្វើឲ្យរលុបរលាយនូវអក្សរ ដែលពីបុរាណកាលមានន័យងងឹតជ្រាលជ្រៅ ពិបាកនឹងយល់ តែមានឥទ្ធិពលអស្ចារ្យអាចញ៉ាំងសត្វាមនុស្សក្នុងកត នៅពេលនោះឲ្យមានឡើងបាន ។ ខ្ញុំបានដឹងនូវព្រះសទ្ធម្មទេសនាដែល ព្រះសម្មាសម្ពុទ្ធបានថ្លែងនៅក្នុងសាយណ្ហសម័យនៃប្រទេសឥណ្ឌា, ខ្ញុំ ដឹងថាមានអ្នកប្រាជ្ញបានចារឹកទុកនូវអ្នកស្លាប់មានចំនួនជាអនេក គឺមនុស្ស កប់សែនរាននាក់, ទេវតាទាំងអស់ និងពួកបិសាចបាននាំគ្នាមក ស្លាប់ត្រៀបត្រា ហើយក្នុងពេលនោះភពលោកចាកចេញស្ងាត់រហូត ដល់ទេវលោកប្រាំពីរជាន់ព្រមទាំងអបាយភូមិទាំងអស់, ក្នុងពេលនោះ រស្មីព្រះសូរ្យាបង្អង់នៅលើនភាល័យខុសពីម៉ោងធម្មតា, បំភ្លឺដោយពណ៌ កុលាបនូវកំពូលភ្នំគិរីខេបមាបីដូចនិសា (យប់) រង់ចាំស្លាប់ក្នុងជ្រោះ បព្វតា ហើយទិនមុខ (ថ្ងៃ) រង់ចាំស្លាប់នៅលើខ្នងភ្នំ; គេបានចារឹក ទុកថា ស្រមោលពោលរូបកាន់គ្នាទៅវិញទៅមកមានសភាពដូចជានាង កញ្ញាទេពអប្សររាំផ្លូលដោយកាមទេពដូចនោះ: ពពកអណ្ដែតខ្ពលខ្ពាញ់ លើអាកាសដូចជាព្រះកេសាអង្កាញ់របស់នាង, តាកក្ដីដូចគជខ្យងនឹង ពេជ្រដែលភ្លឺចាំងពីម្កុដនាង ព្រះចន្ទពោលរស្មីភ្លាំងម្កុដ ហើយយប់ងងឹត ជាព្រះពស្ត្ររបស់នាង ។ ខ្យល់អស្សាសៈបស្សាសៈរបស់នាងបក់ចេញ មិនដាច់ ផ្សព្វផ្សាយពាសពេញពលមានក្លិនផ្សេង ៗ, ហើយក្នុងពេល នោះព្រះសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់សំដែងព្រះសទ្ធម្មទេសនា, ហើយបើ

អ្នកណាស្តាប់ព្រះឱវាទ, បើទុកជាអសេយ្យសាសន៍ ឬទាសកម្មករ មានវណ្ណៈខ្ពស់ទាបឬជាតិអារ្យៈឬម្លិចឆ (mleicha)(១) ឬពួកអរញ្ញជន ទៅជាស្តាប់ឮតាមភាសារបស់ជាតិខ្លួន ៗ មិនតែប៉ុណ្ណោះ, គេបាននិពន្ធទុកថាជនជាតិធំ-តូចដែលនៅតាមមាត់ស្ទឹង, សត្វតិរច្ឆាន, បក្សាទឹងពួកឧរគសត្វ ទៅជាមានចិត្តស្រឡាញ់ព្រះសម្មាសម្ពុទ្ធពន់ពេក, ទទួលក្រេបនូវឱជារសនៃឱវាទព្រះអង្គ បានជាជីវភាពនៃសត្វទាំងអស់នៅក្នុងទម្រង់ សត្វស្វា, ខ្លាដំបង, ប្រើស, ខ្លាឃ្មុំ, ចចក, ឆ្កែព្រៃ, ត្មាតអាស្រ័យគម្រង់ លលកទ្រាំងពណ៌ប្រផេះក្តី ឬក្អែកមានស្លាបក្តីដូចត្បូង, គ័ង្គក់សម្បុំស្រៀម, ពស់មានស្រកាក្តី, បន្ទយ, ប្រជៀវ ឬជាមច្ឆាហែលក្នុងទឹកស្ទឹង, បានឆ្លងទៅដល់ដែនកាតរភាព ចំពោះមនុស្សជាតិដែលមានលក្ខណៈស្លូតត្រង់ មិនស្មើនឹងសត្វតិរច្ឆាន, ហើយមានបីតិប្រាមោជ្ជៈសប្បាយក្នុងហទយវត្ថុដោយបានយល់ថា ចំណងដែលចងសត្វឱ្យនៅក្នុងទាសភាព ដាច់ខ្ទាតខ្ចាយពាកសន្តានអស់រលីង, ហើយព្រះសម្មាសម្ពុទ្ធទ្រង់បានព្រះរាជទានព្រះឱវាទចំពោះព្រះមហាក្សត្រថា :

ឱម, អមិតយៈ ! កុំឱ្យចងពិសោធន៍ល្បងនឹងវាចានៃអនន្តមាត្រ (Incommensurable) ឬដែមុជខ្សែចិន្តាទៅក្នុងអវិជ្ជនភេព (Impénétrable) អ្នកណាសួរការប្រឡំ, អ្នកណាឆ្លើយ, ការប្រឡំ, ៗ កុំឱ្យនិយាយអ៊ី ?

(មានគ)

---

១ ម្លិចឆ: ជាពួកអនារ្យជន, ជានាមដែលពួកអារ្យជនហៅចំពោះពួករដ្ឋភិសី ដែលស្ថិតនៅប្រទេសឥណ្ឌា ។

# សុខោទាយកថា

## ព្រះអាចារ្យទូប-ឡេង វត្តកែវព្រះភ្លើង ក្រុងភ្នំពេញ

ទេសនាដាក់វិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៥ កើត ខែពិសាខ ឆ្នាំជូត
សំរិទ្ធិស័ក ព.ស. ២៤៩១ (២២—៥—៤៨)

---

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ខ្ញុំព្រះករុណា សូមបង្អោនកាយ-វាចា-ចិត្ត ក្រាបថ្វាយបង្គំចំពោះ ព្រះពុទ្ធព្រះធម៌ព្រះសង្ឃ ដោយសេចក្ដីគោរព ។

លំដាប់តពីនេះទៅ អាត្មាភាពសូមសំដែងនូវព្រះសទ្ធម្មទេសនា ដើម្បីបំភ្លឺការសុខ-ទុក្ខគ្រប់ចំពូក តាមរបៀបច្បាប់ព្រះពុទ្ធសាសនា ដែលមានចារិកទុកក្នុងព្រះត្រៃបិដក ផ្សាយចែកជូនដល់អស់លោក-អ្នក កាន់ព្រះពុទ្ធសាសនា ដោយសង្ខេបដូចតទៅនេះ :

សព្វសត្វទាំងឡាយ សុទ្ធតែស្វែងរកសេចក្ដីសុខគ្រប់ៗប្រាណ តែមិនងាយនឹងបានជួបប្រទះនូវសេចក្ដីសុខនោះសោះ ដូចយ៉ាងខេមរៈ ជនយើងនេះ ច្រើនតែជួបប្រទះនូវសេចក្ដីទុក្ខលំបាក ច្រើនជាងជនជាតិ នានា នោះមិនមែនមកពីយើងកាន់ព្រះពុទ្ធសាសនាទេ ប្រាកដជាមកពី យើងមិនដឹងច្បាប់ព្រះពុទ្ធសាសនាឲ្យច្បាស់លាស់ ឬក៏យើងដឹងដែរ តែយើងមិនប្រតិបត្តិតាមឲ្យសព្វគ្រប់ បានជាយើងឃ្លាងចាកសុខ ដែល គួរបានអំពីផ្លូវព្រះពុទ្ធសាសនា ។

ហេតុនេះ អាត្មាភាពសូមពណ៌នាអំពីផ្លូវសុខ ។ ពាក្យថាសុខ ។ នេះបានដល់សេចក្តីសប្បាយ រីករាយ ធូរទូលាយ ស្រួលនៃកាយ - និងចិត្ត ។ ឯសុខ សម្រាប់មនុស្សជាតិ ក្នុងសកលលោកនេះ លោកចែកចេញជា៦ពួកគឺ :

១ – សុខរបស់អ្នកគ្រប់គ្រងផ្ទះ ។

២ – សុខរបស់មនុស្សមួយរូប ។

៣ – សុខរបស់អ្នកមានប្តីប្រពន្ធ ។

៤ – សុខរបស់អ្នកជាមាតាបិតា និងកូនប្រុស - ស្រី ។

៥ – សុខរបស់អ្នកជានាយ ចៅហ្វាយ និងកូន - កម្ម ។

៦ – សុខរបស់គ្រូអាចារ្យ និងកូនសិស្ស ។

សូមអធិប្បាយមួយពួកម្តង ៗ ដោយសេចក្តីសង្ខេបដូចតទៅនេះ

**សុខរបស់អ្នកនៅគ្រប់គ្រងផ្ទះ** — ជនជាគ្រហស្ថអ្នកមានផ្ទះសំបែងក្រុមគ្រួសារនៅក្នុងស្រុកភូមិមួយ ៗ នោះ លុះតែបានប្រព្រឹត្តប្រតិបត្តិនូវ "ឃរាវាសធម៌" ទើបកើតសុខ ។ ឃរាវាសធម៌នោះមាន ៤ យ៉ាងគឺ:

១ – សច្ចៈ ត្រូវប្រតិបត្តិរក្សាសេចក្តីពិតត្រង់ និងមិនកុហកបោកបញ្ឆោតដល់គ្នា ដោយផ្លូវលក់ដូរជំនួញជួញប្រែផ្សេង ៗ ឬគាំងសមាគមក្រុមហ៊ុនអ្វី ៗ ជាដើម ។

២– ទម: ត្រូវប្រព្រឹត្តបន្ទន់កាយ វាចា ចិត្តឲ្យទន់ភ្លន់នឹងមិនរំលោភបំពានទៅរកគ្នា ដោយកំលាំងលោភ: ទោស: មោហ: ជាដើម ៗ

៣– ខន្តី ត្រូវមានអំណត់អត់ធន់មិនខឹងចំពោះអ្នកនៅរួមនឹងអត់ធន់ចំពោះការងារដ៏លំបាក ៗ ដែលខ្លួនត្រូវធ្វើ ដូចកសិកម្មពាណិជ្ជកម្ម ជាដើម ៗ

៤– ចាគ: ត្រូវលះវត្ថុឲ្យជាប្រយោជន៍ដល់អ្នកនៅជាមួយ ដែលគួរចែកជាដើម ៗ

**សុខរបស់មនុស្សមួយរូប ៗ** — មនុស្សម្នាក់ៗដែលតាំងចិញ្ចឹមជីវិតខ្លួនឲ្យរស់នៅបានសុខក្នុងបច្ចុប្បន្ននោះ លុះតែប្រកបដោយសុខរបស់អ្នករស់នៅ ៤ យ៉ាងគឺ :

១ – សុខកើតអំពីមានទ្រព្យសម្បត្តិដ៏បរិបូណ៌ ៗ ឯទ្រព្យសម្បត្តិរបស់បុគ្គលម្នាក់ ៗ ដែលពេញបរិបូណ៌បាននោះ លុះតែប្រកបដោយសម្បទា ៤ យ៉ាងទៀត គឺត្រូវមានការប្រឹងប្រែងខ្នះខ្នែងស្វែងរកភោគ-សម្បទតាមផ្លូវទឹកផ្លូវគោកដោយលក់ចេញទិញចូល ចំណូលចំណាយឲ្យច្រើន ១, ត្រូវឲ្យចេះរក្សាថែទាំទ្រព្យសម្បត្តិ ដែលរកបានមកនោះឲ្យគង់វង់នៅមាំជាប់ឋិតថេរល្អ ១, ត្រូវឲ្យចេះសេពគប់មិត្តល្អៗ គឺលោកបណ្ឌិតនឹងលោកសក្តិធំៗ ឲ្យបានជាទីទំនុកទុកចិត្ត ១, ត្រូវឲ្យចេះចាយធនធានឲ្យមានប្រយោជន៍ នឹងចេះលៃលកសុំថៃគៃគ្នេររិះរេឲ្យសមល្មម

តាមកំឡាំងដែលគេបាន គឺមិនចំណាយចាយរាយខ្ជះខ្ជាយឲ្យហួសកម្លាំងដែលគេបាន១ ។

២ – សុខកើតអំពីបានចាយទ្រព្យ ។ ជនខ្លះមានទ្រព្យមិនចេះចាយ, អ្នកចេះចាយតែងចាយទំនុកបំរុងលោកមាតាបិតារបស់ខ្លួនឲ្យបានសុខរីករាយផង ចាយចិញ្ចឹមក្រុមគ្រួសារឲ្យបានរុងរឿងផង ចាយក្នុងកាលដែលខ្លួនមានទោសគ្រោះថ្នាក់ផង ។

៣ – សុខកើតអំពីមិនមានចំពាក់បំណុលគេ ។ ការណ៍ដែលមិនចំពាក់បំណុលគេនោះ លុះតែបុគ្គលនោះវៀរបង់ទោសពីរយ៉ាង គឺជាអ្នកមិនបង្កហេតុឲ្យកើតក្តីក្តាំដល់គ្នានឹងគ្នា ១, មិនប្រព្រឹត្តអបាយមុខដែលជាគ្រឿងវិនាសមានលេងស្រី - ស្រា - បៀ - ប៉ោ ជាដើម ១ ។

៤ – សុខកើតអំពីប្រកបការងារប្រាសចាកទោស ។ ការណ៍ដែលប្រកបការងារប្រាសចាកទោសនោះ លុះតែជាអ្នកប្រតិបត្តិឲ្យល្អត្រឹមត្រូវតាមច្បាប់ព្រះរាជអាណាចក្រស្តេចផែនដី មានមិនប្រព្រឹត្តចោរ-កម្មលួចប្លន់ជាដើម ។

សុខរបស់អ្នកមានប្តី-ប្រពន្ធ— បុរសស្ត្រីដែលបានគ្នាជាគូស្រករហើយ ត្រូវប្រតិបត្តិធម៌ប្រាំៗ ម្នាក់ ទើបកើតសុខដល់គ្នាបាន គឺប្តីត្រូវទំនុកបំរុងប្រពន្ធរបស់ខ្លួនដោយធម៌ ៥ យ៉ាង:

១ – ត្រូវពប់អានលើកមុខប្រពន្ធថាជាប្រពន្ធពិតប្រាកដ ។
២ – ត្រូវកុំមើលងាយប្រពន្ធរបស់ខ្លួន ដូចជាទាសី ។
៣ – ត្រូវកុំក្បត់ចិត្តប្រពន្ធដោយមានស្រីដទៃទៀត ។
៤ – ត្រូវប្រគល់ការងារក្នុងផ្ទះឲ្យប្រពន្ធត្រួតត្រា ។
៥ – ត្រូវរកគ្រឿងអលង្ការឲ្យប្រពន្ធ ។

ចំណែកប្រពន្ធត្រូវប្រតិបត្តិស្វាមីដូចជាទេវតាក្នុងផ្ទះ ត្រូវគោរពស្វាមីដោយធម៌ ៥ យ៉ាង គឺ :

១ – ត្រូវចេះតាក់តែងគោជនាហារឲ្យមានរសជាតិឆ្ងាញ់ពីសារជូនស្វាមីដូចជានាង "អមរា" កាលបាត់តែងបំរើព្រះមហោសថជាស្វាមីរបស់នាងដូច្នោះ ។

២ – ត្រូវពប់អានញាតិមិត្ត-វង្សត្រកូលខាងស្វាមី ។
៣ – ត្រូវកុំក្បត់ចិត្តប្តីដោយមានប្រុសដទៃ ។
៤ – ត្រូវចេះថែទាំទ្រព្យសម្បត្តិដែលស្វាមីរកបានមក យកទៅទុកដាក់ឲ្យស្រួលបួលល្អ គឺមិនមែនជាស្រីខ្ជះខ្ជាយ ។

៥ – ត្រូវជាស្រីឈ្លាសវៃ ក្នុងការគ្រប់គ្រងផ្ទះ ទាំងជាអ្នកមិនខ្ជិលច្រអូស ក្នុងកិច្ចការទាំងពួង គឺដូសដុល ដេរ ប៉ះ គ្រប ប៉ាក់ ចាក់អន្លូង ត្បាញ រវៃ ការខាងស្រីទាំងប៉ុន្មានត្រូវឲ្យចេះស្ទាត់ទាំងអស់ ។

សុខរបស់អ្នកជាមាតា-បិតានឹងកូនប្រុសស្រី — ជនជាមាតាបិតាអាចទទួលសុខអំពីកូនប្រុស-ស្រីបាននោះ លុះតែបានសង្គ្រោះកូនដោយធម៌ ៥ យ៉ាងគឺ:

១ – ត្រូវហាមឃាត់កូនកុំឲ្យធ្វើអំពើអាក្រក់ឲ្យសោះ, ត្រូវខំបង្ហាត់ពត់បង្វឹកកូនតាំងពីនៅតូច ៗ ឲ្យមានសណ្ដាប់ធ្នាប់ល្អ ។

២ – ត្រូវដឹកនាំកូន ឲ្យតាំងនៅក្នុងសុចរិតទាំង ១០ មានកាយសុចរិតជាដើម ។

៣ – ត្រូវដឹកនាំកូនប្រុស-ស្រីឲ្យរៀនដម្រេះវិជ្ជាផ្លូវលោកផ្លូវធម៌ឲ្យបានចេះដឹង ត្រូវទំនុកបំរុងកូនឲ្យចូលសាលាសិក្សា ឲ្យចេះដឹងអក្សរសាស្ត្រភាសាសាស្ត្រ លេខក្បាច់-នព្វន្ត ជញ្ជីង-នាឡិ-ហាប-រង្វាស់រង្វាល់ក្បួនច្បាប់ សម្រាប់លោកិយគ្រប់ផ្លូវ ។ ត្រូវស្រឡាញ់គ្រូដែលបង្រៀនកូនរបស់ខ្លួន ត្រូវជូនចំណីអាហារដល់គ្រូរបស់កូនខ្លួននោះតាមផ្លូវតាមកាលដ៏គួរ ។

៤ – លុះកូនប្រុសស្រីធំចំរើនឡើងល្មមរកស្វាមី-ភរិយាឲ្យ គប្បីផ្សំផ្គុំឲ្យល្មមតាមវង្សត្រកូលរបស់ខ្លួន ។

៥ – ត្រូវបែងចែកទ្រព្យមត៌កឲ្យកូនប្រុស-ស្រី ឲ្យមានគ្រឿងសំគាល់ជាប្រាកដ ឲ្យកូនមានឋានៈល្អ តាំងពីខ្លួននៅរស់ ដើម្បីការពារសេចក្ដីសុខដល់កូន ។

. ចំណែកកូនប្រុស - ស្រី ត្រូវគោរពប្រតិបត្តិមាតា - បិតា ដោយកិច្ចតបគុណឧបការធម៌ ៥ យ៉ាងគឺ:

១ - ត្រូវចិញ្ចឹមមាតាបិតា ឲ្យបានរស់នៅជាសុខ ឲ្យដូចជាលោកចិញ្ចឹមខ្លួន ។

២ - បើមាតាបិតាកំពុងធ្វើកិច្ចការណា យើងជាកូនត្រូវនាំគ្នាជួយធ្វើកិច្ចការនោះជូនលោក, បើលោកចាស់ជរា ត្រូវថែទាំរក្សាបំរើដោយទឹកក្តៅត្រជាក់ត្រប់យ៉ាង, វេលាមាតាបិតាចូលដំណេក ត្រូវគក់ច្របាច់ដកជើងដៃ, ទឹងរែតសរសៃជូនលោក, វេលាលោកមានជម្ងឺត្រូវមើលព្យាបាលដោយថ្នាំពេទ្យ ហូប្រចាំការ ។

៣ - ត្រូវរក្សាវង្សត្រកូលរបស់មាតាបិតាឲ្យតាំងនៅល្អ ។

៤ - ត្រូវប្រតិបត្តិខ្លួនឯងឲ្យបានសមរម្យល្មមឲ្យមាតាបិតាទំនុកបម្រុងទុកចិត្តបាន ជាអ្នកគួរទទួលយកទ្រព្យកេរ្តិ៍មត៌កបាន ល្មមលោកចែកឲ្យដោយងាយ ។

៥ - វេលាមាតាបិតាធ្វើកាលកិរិយាទៅ កូនប្រុស - ស្រីត្រូវនាំគ្នាធ្វើសរីរកិច្ចតាមធនធានត្រប់គ្នា រួចត្រូវធ្វើបុណ្យទក្ខិណាទានឧទ្ទិសផ្សាយផលជូនដល់លោក ។

ឯកិច្ចទាំង ៥ យ៉ាងនេះ បើកូនប្រុស - ស្រីណាបានធ្វើហើយ កូនប្រុស - ស្រីនោះ លោកហៅថាជាអ្នក "កតញ្ញូកតវេទី" ។

សុខរបស់លោកជានាយចៅហ្វាយនិងកូនក្ស័យ — ពួកជនដែលនៅជែកគោន ឬធ្វើការស៊ីឈ្នួលនៅក្រោមបង្គាប់របស់លោកជានាយចៅហ្វាយណា នាយចៅហ្វាយនោះត្រូវសង្គ្រោះដល់បាវព្រាវ ឬកូនក្ស័យនោះដោយធម៌ ៥ យ៉ាង គឺ

១ – ត្រូវចេះចាត់ចែងការឲ្យស្អាតជំនាញ ហើយចេះលៃលកការឲ្យសមគួរដល់កំលាំងនិងដម្រេះវិជ្ជាដែលបាវព្រាវកូនក្ស័យល្មមធ្វើបាន ។

២ – ត្រូវតាំងចិត្តអាណិតបាវព្រាវ - កូនក្ស័យឲ្យស្មើៗគ្នា, ត្រូវចែករង្វាន់ប្រាក់កាស ឲ្យបរិភោគបាយរាយល្មមគ្រប់គ្រាន់ ។

៣ – ត្រូវថែទាំបាវព្រាវ - កូនក្ស័យ ក្នុងវេលាមានជម្ងឺឈឺចាប់ត្រូវជួយព្យាបាលថ្នាំនិងរកពេទ្យ - ហ្វ ជួយការពារក្នុងវេលាមានទោសទុក្ខគ្រោះថ្នាក់ផ្សេងៗ ។

៤ – ត្រូវចែកលាភៈសក្ការៈ និងអាហារដែលមានឱជារសប្លែកៗ ឲ្យបាវព្រាវ - កូនក្ស័យបរិភោគផង ។

៥ – ត្រូវបើកឲ្យបាវព្រាវ - កូនក្ស័យបានសប្បាយតាមរដូវ ត្រូវមានពេលឈប់សម្រាក មានរដូវបួលឆ្នាំជាដើម ។

ចំណែកបាវព្រាវ - កូនក្ស័យ ត្រូវប្រតិបត្តិលោកនាយចៅហ្វាយដោយធម៌ ៥ យ៉ាងដែរ គឺ :

១-ត្រូវក្រោកឡើងធ្វើការមុននាយចៅហ្វាយ ជាអ្នកមិនខ្ជិលច្រអូសប្រចែប្រចាំ នឹងនាយចៅហ្វាយឡើយ ។

២-ត្រូវធ្វើការងារ ជាខាងក្រោយនាយចៅហ្វាយ មិនហ៊ានផ្តើមការងារមុននាយចៅហ្វាយ លុះតែការណាដែលលោកអនុញ្ញាតឲ្យ ទើបខ្លួនត្រូវធ្វើការនោះបាន ។

៣-ត្រូវទទួលយកតែរបស់ដែលនាយចៅហ្វាយឲ្យ ។

៤-ត្រូវធ្វើការងារឲ្យត្រឹមត្រូវល្អជូននាយចៅហ្វាយ ។

៥-បាវព្រាវ-កូនឈ្នួលត្រូវនាំយកគុណសម្បត្តិ នឹងសមត្ថភាពរបស់នាយចៅហ្វាយ ទៅសរសើរអួតប្រាប់គ្នាទីប្រជុំជន នឹងមិត្តអាមាត្យធំ ៗ ជាដើម ។

សុខរបស់គ្រូនឹងកូនសិស្ស - ចំណែកគ្រូដែលគួរទទួលសុខអំពីកូនសិស្សបាននោះ លុះតែសង្គ្រោះកូនសិស្ស ដោយធម៌ ៥ យ៉ាងគឺ :

១-ត្រូវដឹកនាំសិស្សឲ្យរៀនដោយល្អ ត្រូវញ៉ាំងសិស្សឲ្យតាំងចិត្តប្រកបដោយសុចរិត យុត្តិធម៌យ៉ាងចំណាន ប្រថ្ងៃថ្នូរ ។

២-ត្រូវដឹកនាំសិស្សឲ្យរៀនច្បាប់ផ្លូវលោក ផ្លូវធម៌ ឲ្យចេះចំណានដើម្បីរក្សាជាតិ-សាសនា មហាក្សត្រ ។

៣- ត្រូវបង្ហាត់បង្ហាញសិល្បវិជ្ជា ដល់សិស្សឲ្យអស់ជម្រះវិជ្ជាពីខ្លួនមិនលាក់លៀមទុក ។

៤- ត្រូវលើកតំកើងសិស្ស ក្នុងទីប្រជុំមិត្តអាមាត្យ មិនបន្ទោសបង្អាប់សិស្សក្នុងទីប្រជុំជន ។

៥- ត្រូវធ្វើសេចក្ដីការពារសិស្ស ក្នុងទិសទាំងពួងថា មិនឲ្យសិស្សលំបាកដោយអាហារជាដើម កុងវេលាមានដំណើរទៅកាន់ទិសទាំងពួង ។

ចំណែកយុវជន នារី ជាសិស្សទាំងឡាយ ត្រូវនាំគ្នាប្រតិបត្តិគោរពគ្រូអាចារ្យរបស់ខ្លួនដោយធម៌ ៥ យ៉ាងគឺ:

១- សិស្សត្រូវនាំគ្នា ធ្វើសេចក្ដីគោរពចំពោះគ្រូអាចារ្យ របស់ខ្លួនមានការបបួលគ្នាក្រោកទទួលគ្រូជាដើម ។

២- សិស្សត្រូវនាំគ្នា ចាំបំរើគ្រូដោយកិច្ចផ្សេងៗ ក្ដីមិនមានកិច្ចអ្វីក្ដីមានទឹកក្ដៅត្រជាក់ជានិច្ចជាដើម ។

៣- សិស្សត្រូវនាំគ្នា ទំនុកបំរុងគ្រូ ពេលណាដែលគ្រូមានអាពាធប្ចុដម្ងំ សិស្សត្រូវរកថ្នាំ ឬពេទ្យហ្នា មកព្យាបាលគ្រូ និងជូនចំណីអាហារផ្សេងៗ ដល់គ្រូរបស់ខ្លួនជារឿយៗ ក្ដី កុំរដូវប្ដូរមួយកាលក្ដី ឬកំរដូវចូលឆ្នាំថ្មីជាដើមក្ដី ។

៤ - សិស្សត្រូវជឿឱវាទដែលគ្រូប្រៀនប្រដៅ គឺត្រូវយកចិត្តទុកដាក់ស្តាប់ឲ្យបានការ ដើម្បីយកទៅធ្វើជាច្បាប់ទម្លាប់របស់ខ្លួនឲ្យចេះចាំប្រាកដចូលចិត្តឲ្យច្បាស់លាស់ ។

៥ – សិស្សត្រូវនាំគ្នារៀនសូត្រដោយគោរព, ពាក្យថារៀនសូត្រដោយគោរពនោះ គឺត្រូវខំប្រឹងប្រែងខ្នះខ្នែងរៀនសូត្រ មិនខ្ជិលច្រអូសក្នុងការសិក្សា បើសិក្សាវិជ្ជាណាៗ ត្រូវឧស្សាហ៍ទន្ទេញឲ្យចេះចាំស្ទាត់រត់មាត់, ចូលចិត្តច្បាស់លាស់ក្នុងសិស្សវិទ្យានោះៗ ទើបឈ្មោះថារៀនសូត្រដោយគោរព ។

ហៃយុវជន-យុវនារី អ្នកត្រូវការសិក្សាសិល្បសាស្ត្រ-អក្សរសាស្ត្រ-វិទ្យាសាស្ត្រ និងនព្វន្តសាស្ត្រ-លេខជាដើម ត្រូវនឹកពិចារណាដល់ច្បាប់លោកនីតិបករណ៍ថា:

កុំមើលងាយមន្តសិល្បសាស្ត្រ គិតថាតិចតួចក្រែងមិនស្រេច
វិជ្ជាមួយមែនបើមិនភ្លេច គង់នឹងសម្រេចប្រយោជន៍បានៗ
ចេះមួយចេះពីរឲ្យតែស្ទាត់ ប្រកបប្រាកដអ្នកបំណាន
ជាហេតុចិញ្ចឹមជីវិតបាន សន្តានដួលពឹងពំនឹងអើយ ។

សិល្បសាស្ត្រឯណាមិនស្ទាត់ពិត នៅក្នុងស្លឹករឹតឬសៀវភៅ
ទ្រព្យធនឯណាដែលមាននៅ ធ្លាក់ទៅក្នុងដៃអ្នកដទៃ ។

បើមានកិច្ចការណាដល់មក  សិល្បទ្រព្យនោះយកមកអាស្រ័យ
ពុំបានដូចចិត្តដ្បិតឆ្ងាយដៃ  សិល្បទ្រព្យនោះនៃហៅគ្មានហោង ។

## សុភាសិតថា :

មានទ្រព្យលើកឲ្យគេខ្ចីទៅ  ដរម្រែះបេះនៅតែក្នុងក្បួន
ប្រពន្ធនៅឆ្ងាយអំពីខ្លួន  ដល់ជួនត្រូវការរអាចិត្ត ។

ធម៌ទេសនាសំដែងមកនេះ  ដើម្បីឲ្យខេមរជនទាំងឡាយស្ទុះក្រោកឡើង ខំប្រឹងប្រែងស្វែងរកសេចក្ដីសុខដល់ខ្លួន  ទឹងដល់ជាតិប្រទេសក្នុងបច្ចុប្បន្ននេះ សូមសន្មតថាចប់តែប៉ុណ្ណោះ ឯរំ ។

ដោយអំណាចនៃធម៌ទេសនានេះសូមឲ្យជាតិ សាសនា មហាក្សត្រនៃខេមរជាតិយើង ចំរើនសេចក្ដីសុខគ្រប់ប្រការអស់កាលជំយូរអង្វែងទៅ ។

ចប់

**ជោគវាសនាញញឹមទទួលចំពោះតែអ្នកក្លាហាន**

អ្នកចិត្តក្លាហានបានជួយជាតិ
យិតយោងឲ្យឃ្លាតទាសភាព
រមែងមានឈ្មោះខ្ពស់ដកាប
បើទុកជុនដាបគង់ទេពជួយ ។

យ. អ.

# រឿងគ្រូសាញ់[1] អ្នកទាំងពូកែ

## លោក ផេង-ជ្រីវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែនិងរៀបរៀង

(ត—ចប់)

ខណៈនោះគ្រូសាញ់ចេញពីក្រោមស្ពានមក ហើយស្រែកថា នែ អាយក្សចិត្តខ្មៅ ! មកយើងច្បាំងគ្នា ! តើអាឯងចូលចិត្តបែបណា ? ចង់អាវុធឬដៃទទេ ? ។

ក្រុងយក្សស្ទុះវ៉ែកមកដល់ ហើយតយុទ្ធជាមួយគ្រូសាញ់ ។ មុន្ត នេះ គេច្បាំងគ្នាដោយអាវុធ ។ មិនយូរប៉ុន្មាន ដាវលំពែងក៏បាក់បែកអស់ ។ រួចការចាប់ផ្តើមវាយគ្នា ដៃនឹងដៃ ក៏តាំងមានឡើង ។ គេច្បាំងគ្នាទាល់តែកម្រើកផែនដី ។ គ្រូសាញ់ដឹងថាការឱបរឹតនៃយក្សកាន់តែតឹងឡើង ។ គាត់បេះប្រឹងចំកោងទប់នឹងកំឡាំងយក្សបាន ហើយចាប់រឹតយក្សទាល់តែលាន់ឆ្អឹងឆ្អែងទាំងអស់ ។

ចម្បាំងបែបនេះ គ្មាននរណាដែលឃើញឡើយ ។ ដល់ថ្ងៃត្រង់ គេក៏នៅតែប្រយុទ្ធគ្នា ស្រេកទឹកខះក អស់កំលាំងតែរៀងខ្លួន ។ វេលានោះ មានក្អែកមួយហើរពីលើ ។ យក្សឃើញដូច្នោះ ហៅថា បងក្អែកៗ មងឯងយកទឹកមកឲ្យអញផឹកមួយលេប អញនឹងឲ្យខ្មោចអ្នកហារហាន ម្នាក់ព្រមទាំងសេះ របស់វា យកទៅស៊ី ។

---

១ ក្នុងរឿងព្រេងរូមម៉ាំងថា «ក្រោសាណូ» អ្នកប្រែបង់ឲ្យស្រួលអាន ទើបបកថា «គ្រូសាញ់» ។

ខណៈ នោះ គ្រសាញ់និយាយម្ដងថា: បងក្អែកៗ យកទឹកថ្លាល្អមកឲ្យខ្ញុំផឹកវិញ នោះខ្ញុំនឹងឲ្យខ្លាបយកប្រើ ទឹងខ្លាបសេះបី ជាលបងឯងជាអាហារ ។

បានឮសំដីគ្រសាញ់ ក្អែកយកទឹកមកឲ្យគាត់ផឹកបំបាត់ការស្រេក ហើយធ្វើឲ្យគាត់មានកំលាំងនឹងសេចក្ដីក្លាហានឡើងវិញ ។ មានកំលាំងភ្លាម គ្រសាញ់ចាប់យក្សលើកឡើងស្ទើង បុកបុះក្នុងដីលិចខ្លួនដល់ក យកជើងជាន់ក្បាល ដើម្បីទប់ឲ្យនឹងហើយស្រែកសួរថា: ម្នាលអាចោរបិសាចចង្រៃ! អាឯងត្រូវប្រាប់អញ តើអាឯងលាក់ព្រះអាទិត្យនឹងព្រះចន្ទក្នុងទីឯណា? ព្រោះពេលនេះ អាឯងមុខជាមិនរួចពីកណ្ដាប់ដៃអញហើយ ។

យក្សខំត្រដររើខ្លួន ឡើងមុខក្រហមឆ្អៅដើម្បីស្រូះរត់ ហើយនិយាយរដ៉ុំៗ តែក្នុងមាត់ ។ គ្រសាញ់និយាយទៀតថា: ទោះបីអាឯងប្រាប់ក៏ដោយ មិនប្រាប់ក៏ដោយ គង់តែអញរកឃើញព្រះចន្ទនឹងព្រះអាទិត្យនោះ. ប៉ុន្តែ អាឯងទៀងតែមានក្បាលដាច់ជាមិនខាន ។

លុះទីបំផុត យក្សមានសង្ឃឹមថា បើប្រាប់កាលណា ប្រហែលបានរួចជីវិត ទើបស្រែកប្រាប់ថា: នៅក្នុងព្រៃបៃតង មានរូងមួយ ក៏ក្នុងរូងនោះហើយដែលអញលាក់ព្រះអាទិត្យនឹងព្រះចន្ទ, កូនម្រាមដៃស្ដាំរបស់អញជាកូនសោ សម្រាប់ចាក់បើករូងនោះ ។

ពុជុំនោះហើយ គ្រសាញ់កាត់ក្បាលយក្សក្រាម រួចកាត់យកម្រាមកូនដៃស្តាំដោយស្រួលបួល ។

ខាងក្រោយដែលបានឲ្យខ្មោចយក្ស ទឹងខ្មោចសេះដល់ក្អែកហើយ គាត់ត្រាច់ទៅក្នុងព្រៃបែតង ឃើញរូងគុហាមួយ យកម្រាមកូនដៃយក្សបាកបើកទ្វារ ហើយឃើញព្រះអាទិត្យនិងព្រះចន្ទ្រនៅទីនោះ ។ គាត់ចាប់ព្រះអាទិត្យដោយដៃម្ខាង ព្រះចន្ទ្រដោយដៃម្ខាងទៀត ហើយបោះទៅលើអាកាសវេហាស៍ រួចគាត់មានសេចក្តីសប្បាយរីករាយរកអ្វីប្រៀបគ្មាន ។

បណ្តាជនទាំងអស់ កាលបើបានព្រះអាទិត្យនិងព្រះចន្ទ្រត្រឡប់វិលមកកាន់ទីគោចរតាមធម្មតាវិញ ក៏មានចិត្តត្រេកអរជាអនេក ថែមទាំងអរគុណចំពោះព្រះជាម្ចាស់ ដែលមានព្រះទ័យមេត្តាជួយកំណាំងដល់គ្រសាញ់ ដើម្បីញ៉ាំងការផ្តាញ់នូវបច្ចាមិត្រ នៃមនុស្សលោកឲ្យបានសម្រេច ។ រួចបុរសហាវហានធ្វើដំណើរយ៉ាងរីករាយវិលមកវិញ ។

ដល់ផ្លូវបំបែក គាត់បានឃើញប្អូនរបស់គាត់ឈប់ចាំនៅទីនោះ ជនទាំងពីរស្ទុះចាប់ឱបគ្នា យំថ្ងូងសេចក្តីសុខទុក្ខចំពោះគ្នាទៅវិញទៅមក ទិញសេះពីរយ៉ាងលឿនដូចព្រួញ ហើយជិះត្រឡប់មកកាន់ព្រះរដ្ឋដើមវិញ ។

នៅតាមផ្លូវ គេបានឃើញទន្ទាប់មួយដើម ពេញដោយផ្លែក្រហមដូចមាស ។ ប្អូនគ្រសាញ់អង្វរបងសុំឈប់ក្រោមម្លប់ទន្ទាប់សិន ដើម្បី

ឲ្យសេះបាត់ហត់ផង បំបាត់សេចក្ដីឃ្លានដោយបរិភោគផ្លែទន្លាប់ទុំមួយពីរម្នាក់ផង ។ គ្របសាញ់ដែលយល់កលនៃមេយក្ខិនី ក៏សុខចិត្តព្រមឈប់តាមពាក្យសុំរបស់ប្អូន ។ ប៉ុន្តែ គាត់មិនបណ្ដោយឲ្យប្អូនគាត់បេះផ្លែទន្លាប់ឡើយ និយាយថា ទុកឲ្យគាត់បេះឲ្យវិញ ។ ទាញកាំបិតលៀមចេញមក គាត់កាប់ដើមទន្លាប់ដាប់ត្រឹមដី ។ គ្រានោះ គេឃើញឈាមពុលគួរស្ញែងហូរបាញ់ឡើងហើយ ឮសូរសំឡេងនិយាយពីក្នុងដើមឈើមកថា: បើអាឯងស៊ីអញតែមួយម៉ាត់ គាត់ឯងទៀងតែស្លាប់ដូចជាប្ដីអញដែរ ។

ក្នុងមួយសន្ទុះតមក ដើមទន្លាប់នោះក៏អន្តរាយបាត់ គេឃើញនៅមានតែផេះនឹងធូលី ។ ចំណែកប្អូនគ្របសាញ់ស្រឡាំងកាំង មិនយល់-សោះនូវរឿងហេតុដែលបានឃើញប៉ុន្មាន ។

បងប្អូននាំគ្នាធ្វើដំណើរតទៅទៀត ។ លុះឆ្ងាយបន្តិចមក ជនទាំងពីរជិះសេះបរក្បែរបឹងមួយដ៏រុងរឿងអស្ចារ្យ ពេញដោយបុប្ផាផ្សេងៗនឹងមេអំបៅគ្រប់ពណ៌ ហើយមានទឹកយ៉ាងថ្លាហូរខាងក្នុង ។

ប្អូនគ្របសាញ់និយាយទៅកាន់បងថា: ត្រូវយើងឈប់ត្រង់នេះបន្តិចសិន បង! សេះយើងនឹងសំរាកបន្ធូរកំលាំង ហើយយើងក៏អាចផឹកទឹកថ្លានេះបំបាត់សេចក្ដីស្រេក ព្រមទាំងបេះផ្កាពីរបីកំសាន្តលេងផង ។

គ្របសាញ់ឆ្លើយថា: មែនហើយ ប្អូន! ប៉ុន្តែ សូមឲ្យបុប្ផជាតិទាំងនោះជារបស់មនុស្សលោកផង ហើយទឹកជារបស់ផងព្រះជាម្ចាស់ ។

ហើយទាញលៀមចេញមក គាត់កាត់ផ្កាមួយដើមយ៉ាងឆើតឆាងគេ ផ្តេកទៅដី រួចយកដើមរុក្ខកងទឹកជ្រោះ ៗ គឺមិនមែនជាទឹកធម្មតា បែរ ត្រឡប់ជាឈាមខ្មៅហូរមកវិញ បំពេញអាកាសដោយក្លិនអសោចក្រៃ ពេក ៗ ម្តងនេះគឺកូនស្រីច្បងនៃមេយក្ខិនី ដែលក្លាយជាផ្កូលី មកនិមិត្ត ជាច្បារទឹកជាជ្រោះ ដើម្បីបំពុលគ្រូសាញ់ឲ្យស្លាប់ ៗ

បានកន្លងផុតពីគ្រោះកាច ម្តងជាពីរដងហើយ ជនទាំងពីរលោក ដែលលើខ្នងសេះបំផាយយ៉ាងលឿនដូចខ្យល់ ៗ មិនយូរប៉ុន្មាន មេយក្ខិនី ជាប្រធានក្រុងយក្ស ហោះតាមមកទៀត ហាមាត់យ៉ាងធំអស្ចារ្យពីដី ដល់មេឃ បំរុងនឹងលេបត្របាក់គ្រូសាញ់តែមួយឃុបឲ្យស្រេច ៗ វាក្តៅ ក្រហាយនឹងគ្រូសាញ់ដែលសំឡាប់ប្តី កូនស្រីនឹងកូនប្រុសរបស់វា ៗ

គ្រូសាញ់ដឹងថា មេយក្ខិនី ដេញតាមមកហើយ ក៏និយាយប្រាប់ ប្អូនថា: នែអូន! ចូរឯងក្រឡេកបែរក្រោយមើល បើឃើញអ្វី ចូរប្រាប់ បង ៗ ប្អូនឆ្លើយថា: គ្មានឃើញអ្វីទេបង! មានតែពពកខ្មៅមួយដុំសោត មកតាមក្រោយយើងលឿនដូចខ្យល់កំបុតត្បូង ៗ

បងប្អូនទាំងពីរ ខំវាយសេះរៀងខ្លួនបំផាយឲ្យលឿនដូចខ្យល់ហើយ ស្ងៀមស្ងាត់ដូចចិត្តទឹក ៗ គ្រូសាញ់ប្រាប់ប្អូនទៀតឲ្យក្រឡេកមើល ក្រោយ ហើយប្អូនប្រាប់ថា ពពកនោះកាន់តែអណ្តែតជិតណាស់មក ហើយ ៗ ដូចជាអណ្តាតភ្លើងផង ៗ គេខំវាយសេះបំបោល លុះទីបំផុត ក៏បានដល់លំនៅជាងដែកផែនដី ៗ

លោកតាពីលើខ្នងសេះ បុរសបងប្អូនរត់ចូលពួនក្នុងកន្លែងដំដែក ។ ទេសកាលល្អសំណាងមាន បើមេយក្ខិនីតាមទាន់ សមនៅសល់តែឆ្អឹង តែឥឡូវក៏រកធ្វើអ្វីមិនកើត ។

ម្តងនេះ មេយក្ខិនីប្រើឧបាយវិញ: ក៏អង្វរសុំឲ្យគ្រូសាញ់ចោះប្រហោងមួយតូចនៅជញ្ជាំង គ្រាន់តែក៏អាចមើលឃើញមុខគ្រូសាញ់ៗធ្វើហាក់ដូចជាយល់ព្រមតាម ។ ប៉ុន្តែនៅខាងក្រោយជញ្ជាំងនោះ ជាកន្លែងរបស់ជាងដែកផែនដី នឹងរូបសំណាកគ្រូសាញ់អ្នកហាវហាន គឺជារូបដែកទាំងដុលទើបតែយកចេញពីភ្លើង មានទាំងព្រាចភ្លើងផុះប្រេះៗទៅទៀយ ។ កាលមេយក្ខិនីយកមាត់ទៅផ្អឹបនឹងរន្ធជញ្ជាំងដើម្បីលេបគ្រូសាញ់ ជាងដែករុញរូបដែកក្រហមឆ្អាំងដាក់មាត់ ហើយរុញឲ្យចូលដល់បំពង់ក ។ មេយក្ខិនីទ្របាក់ក្អាម ហើយបែកពោះផ្ទុង ។ ខ្មោចក៏ក្លាយទៅជាក្អែកមួយរំពេច ។ សំឡាញ់យើងពីរនាក់ ក៏បានរួចជីវិតដោយសារ ។

គ្រានោះជាងដែកផែនដី បើកទ្វារបន្ទប់ដំដែក បងប្អូនទាំងពីរចេញមក មានសេចក្តីសប្បាយរីករាយអស់បីថ្ងៃបីយប់ អំពីជ័យជំនះដ៏ធំនេះ ។ ជាងដែកផែនដីសប្បាយជាងគេ ដោយបានក្អែកមួយធំ យកឲ្យកូនជាងធ្វើទេះដែកបីទឹមដោយសេះដែកបីដែរ គាត់ផ្លុំបញ្ចូលវិញ្ញាណក្នុងរូបសេះទាំងនោះឲ្យមានជីវិត រួចប្រគល់ឲ្យគ្រូសាញ់ជាសំឡាញ់ ។ អ្នកហាវ

បានទេះលាសំឡាញ់ ឡើងជិះទេះជាមួយនឹងប្អូន ហើយធ្វើដំណើរទៅកាន់ព្រះបរមរាជវាំងនៃព្រះបាទរត្ន ដើម្បីសូមយកផ្កាន់ ។

ជនទាំងពីរទៅជាមួយគ្នា រហូតដល់ផ្លូវបំបែកមួយ ហើយឈប់សំរាកក្នុងទីនោះ ។ រួចគ្រូសាញ់ ដោះសេះឲ្យទៅប្អូន ដើម្បីទៅមុន យកដំណឹងទៅថ្វាយ ព្រះរាជាអំពីការវិលត្រឡប់ត្រឡប់ដោយជ័យជំនះ ។ ខ្លួនគាត់ចាំទៅជាខាងក្រោយ ។

ចំណែកគ្រូសាញ់កំពុងតែធ្វើដំណើរបន្តិចៗ ដេកលេងក្នុងរទេះស្រាប់តែត្រាច់ទៅក្បែរបិសាច កំបាក់ជើងមួយនៅខាងផ្លូវដែលមានកិច្ចខាងចាំធ្វើទុក្ខដល់អ្នកដំណើរទាំងឡាយ ។ បិសាចនោះមិនហ៊ានធ្វើបាបគ្រូសាញ់ តែមិនបង់ឲ្យគាត់ទៅដោយគ្មានអន្តរាយតែអ្វីមួយ ក៏លួចដកដែកគោលមួយដែលបោះភ្ជាប់ដុំកង់ខាងក្រោយ យកបោះចោលទៅខាងក្រោយឆ្ងាយ ហើយស្រែកថា នែសំឡាញ់! ដុំកង់ក្រោយរដេកធ្លាក់ហើយៗ

លោកចុះពីរទេះទៅដី គ្រូសាញ់ភ្លេចកាន់លៀមទៅផង ។ បិសាចឈ្មោះសាគានលួចយកលៀមបាន រួចលោកបីដង ក៏ក្លាយខ្លួនទៅជាថ្មមួយដុំនៅក្បែរថ្នល់ ។

គ្រូសាញ់រើសយកដែកគោលមកវិញ យកទៅបោះភ្ជាប់ត្រង់កន្លែងដដែល រួចបររទេះតទៅទៀត មិនបានចាប់ក្តីអំពីលៀមបាត់ឡើយ ។

ក្នុងគ្រានោះ មានទីប្រឹក្សាព្រះរាជាណាចក្រម្នាក់ចិត្តអាក្រក់ បានសន្យាថានឹងឲ្យដួងវិញ្ញាណនៃខ្លួនដល់បិសាចសាគាន បើបិសាចនេះ

អាចយកកូនស្ដេចមកឲ្យវាធ្វើជាប្រពន្ធបាន ។ ម្យ៉ាងទៀត អាចិត្តអាក្រក់នេះ បានទាំងទៅសហាយជាមួយនឹងព្រះរាជធីតារួចហើយផង ។ ចំណែកអាបិសាចចាដែលបានដឹងច្បាស់ថា តេជានុភាពនៃគ្រូសាញ់ស្ថិតនៅក្នុងលៀម ។ ហេតុដូច្នេះ បានជាវាខំលួចយកលៀមទៅប្រគល់ឲ្យទីប្រឹក្សាចំកួតនេះ ។ ឥស្សរជននេះ លុះបានលៀមហើយ ក៏ចូលទៅគាល់ព្រះរាជាក្រាបបង្គំទូលនូវស្នាដៃនៃគ្រូសាញ់ថាជាស្នាដៃរបស់ខ្លួន ។

ព្រះមហាក្សត្រទ្រង់ជឿតាម ។ រួចគេកំពុងតែរៀបចំប្រដាប់ប្រដា ដើម្បីនឹងធ្វើអាពាហ៍ពិពាហ៍រវាងទីប្រឹក្សា នឹងព្រះរាជធីតា ស្រាប់តែប្អូនគ្រូសាញ់មកដល់ ហើយថ្វាយដំណឹងជ័យជំនះ ទឹងការជិតមកដល់នៃគ្រូសាញ់ ចំពោះព្រះរាជា ។

បានដំណឹងនេះ ទីប្រឹក្សាទៅគាល់ព្រះរាជាភ្លាម ហើយក្រាបទូលទាស់ថា អ្នកដែលមកថ្វាយដំណឹងនេះគឺជាមនុស្សបោកបញ្ឆោតទេ គួរតែព្រះករុណាយកទៅដាក់គុកទើបសម ។ ព្រះរាជាទ្រង់យល់តាម ។ កាលបើទីប្រឹក្សាបង្គំព្រះរាជាឲ្យប្រញាប់ រៀបអាពាហ៍ពិពាហ៍ ព្រះអង្គត្រឡប់ជាមិនសព្វព្រះរាជហឫទ័យ ហើយថែមទាំងបន្ថយថ្ងៃមង្គលការនោះទៅទៀត (អាចិត្តអាក្រក់គិតឃើញថា ឲ្យតែបានរៀបការហើយ ទោះគ្រូសាញ់មកក៏មិនអាចផ្លាស់ប្ដូររឿងនេះបានឡើយ) ។

មិនយូរប៉ុន្មាន គ្រូសាញ់មកដល់ នៅក្រាបបង្គំគាល់ព្រះរាជាដែលទ្រង់មិនដឹងជាយកណាពេលណា ។ ព្រះរាជាទ្រង់ជឿគ្រូសាញ់ដែរ

ប៉ុន្តែ ទាស់ត្រង់កាំបិតលៀម ហេតុដូចម្តេច ក៏មកនៅក្នុងដៃនៃទ័ប្រែក្បាវិញ! ។ ពេលនេះហើយទើបគ្រូសាញ់ភ្ញាក់ខ្លួនដឹងបាត់លៀម ហើយនឹកដល់ថ្មមួយដុំនៅក្បែរថ្នល់ដែលគាត់ប្រទះឃើញ ក្នុងវេលាដែលគាត់ត្រឡប់មកពីរើសដែកគោលវិញ ។ ដឹងច្បាស់ថាជាក់ជាមានហេតុកើតត្រង់ទីនោះហើយ គ្រូសាញ់ក៏ក្រាបទូលព្រះរាជាថា បពិត្រព្រះមហាក្សត្រដ៏ទ្រង់យសខ្ពង់ខ្ពស់ ទសពិធរាជធម៌នៃព្រះករុណាថ្លៃវិសេស តែងទៅពាសពេញព្រះរាជរដ្ឋ! បើដូច្នេះ សូមទ្រង់ផ្សាយសេចក្តីសប្បុរសនេះដល់ទូលព្រះបង្គំជាខ្ញុំផង, ព្រះអង្គទ្រង់ព្រះខន្តីយូរណាស់មកហើយ ឥឡូវសូមព្រះមេត្តាអត់ទោសបន្តិចទៀត នោះទ្រង់នឹងឃើញការពិតចំពោះព្រះនេត្រជាមិនខាន ។

ព្រះរាជាក៏ទ្រង់យល់ព្រម ។ ហើយគ្រូសាញ់ត្រឡប់ឡើងជិះរទេះដែកបរវិលទៅរកដុំថ្មនោះ ហើយស្រែកថា នែអាកំបាប! អាមហាចោរដល់មនុស្សលោក អាឯងលួចលៀមអញ ត្រឡប់ឲ្យមកអញវិញ បើមិនដូច្នោះទេ អាឯងមុខជានឹងល្អិតជាផង់ធូលីទៅទៀតឥឡូវ ។

ប៉ុន្តែ ដុំថ្មនៅព្រងើយ ឥតករម្រើក ។ គ្រានោះគ្រូសាញ់លោតបង្កនិម្មិតខ្លួនជាដុំដែក យ៉ាងរឹងមាំហើយស្វិត តាំងហោតទង្គិចពីលើដុំថ្មយ៉ាងខ្លាំងអស្ចារ្យទាល់តែញ័រផែនដី ។ ក្នុងការលើកអុកពីលើម្តងៗ មានខ្នាតកំទេចថ្មចេញព្រាតៗ ។ ហើយការលោតអុកនេះគ្មានឈប់ឈរ

នោះ ទាល់តែកំពូលដុំថ្មបែកខ្ទេចខ្ទី អស់រលីង ៗ កាលណោះ ដុំថ្មចាប់កម្រើកហើយសូមទោស ៗ ប៉ុន្តែដុំដែកអុកជានិច្ចកាន់តែខ្លាំងឡើង ៗ ឥតបង្អង់នោះ ទាល់តែដុំថ្មបែកម៉ដ្ឋទៅជាធូលី ៗ ត្រសាញ់កកាយរកកន្ទូលីថ្ម ហើយបានឃើញល្មៀម ដែលបិសាចសាតានលួចយកពីគាត់ទៅនោះមកវិញ ៗ

គាត់កាន់ល្មៀមរត់ទៅយ៉ាងលឿនឥតបង្អង់ ចូលបង្គំគាល់ព្រះរាជាម្តងទៀតហើយនិយាយថា បពិត្រព្រះមហាក្សត្រដ៏ទ្រង់រិទ្ធិ! ទូលព្រះបង្គំប្រឹងស្រេចហើយ នឹងសំដែងរិទ្ធិថ្វាយ តើឈ្មោះណាអាចតវ៉ាថាជាស្នាដៃនៃត្រសាញ់, សូមឲ្យអាចោរអប្រិយឥតខ្មាសដែលវាបានបំភាន់ព្រះអង្គចូលមក ហើយយើងនឹងដដែកគ្នាល្បងមើល ៗ

ព្រះរាជាមានព្រះរាជឱង្ការបង្គាប់ឲ្យគេហៅទីប្រឹក្សាចូលមក ៗ អ្នកនេះ លុះបានឃើញកាំបិតល្មៀមកាលណា ក៏ញាក់ដូចកូនសត្វ សុំទោស ហើយព្រមទទួលកំហុសទាំងអស់ ៗ

ដោយសេចក្តីអង្វររបស់ត្រសាញ់ ព្រះរាជាក៏ទ្រង់ព្រមអត់ទោសដល់ទីប្រឹក្សា ប៉ុន្តែព្រះអង្គទ្រង់និរទេសឲ្យចេញពីរាជរដ្ឋ របស់ព្រះអង្គ ៗ

រួចព្រះរាជាទ្រង់បង្គាប់ ឲ្យគេដោះលែងប្អូនត្រសាញ់ចេញពីគុក ហើយតាំងរៀបអាពាហ៍ពិពាហ៍ ជាឧឡារិកអស់បីថ្ងៃបីយប់ប្រកបដោយសេចក្តីសប្បាយរីករាយយ៉ាងក្រៃលែង ៗ

ចប់

កិច្ចការបណ្ដុះនិស្ស័យ

ព្រះមហាឧត្តមវិជ្ជា ធិលញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

យុនបណ្ណានុរក្ស ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

និស្ស័យសុភាពនេះ មានអំណាចខ្លាំងក្លាក្រៃលែងជាងអំណាចទឹងកំហ្លាំងដទៃទាំងអស់ក្នុងលោក ។ សូម្បីមនុស្សពាល ដែលមានមានះរឹងត្អឹង រឹងរូសប្រឆាំង អាចធ្វើសេចក្ដីអាក្រក់ ចំពោះនរណា ។ បានដោយឥតរើសមុខ មិនកោតក្រែងចំពោះអំណាចអ្វីមួយនោះ ក៏គង់តែកោតក្រែងចំពោះអ្នកដែលខ្លួនដឹងថា ជាមនុស្សមាននិស្ស័យសុភាពចំពោះខ្លួនដែរ ។ ការហាមប្រាមទាំងឡាយ បើហាមប្រាមដោយអំណាចមិនសម្រេច ក៏អាចហាមប្រាមឲ្យសម្រេចដោយនិស្ស័យសុភាពបាន ។ ការគំរាមកំហែង ជាគ្រឿងបង្កឲ្យកើតការមើលងាយប្រឆាំងរឹងរូស ។ ឯនិស្ស័យសុភាពវិញ មានអំណាចឲ្យកើតសេចក្ដីស្រឡាញ់នឹងជឿស្ដាប់ ធ្វើឲ្យខាងអ្នកជួយនឹងខាងអ្នកទទួលដឹងគុណគឺសេចក្ដីល្អដែលបានធ្វើចំពោះគ្នា ។ ខាងអ្នកទទួល សូម្បីមិនដឹង កាលនឹកមក

ដល់ត្រង់រឿងនេះ ក៏គង់នឹងកើតសេចក្ដីដឹង មានកតញ្ញូដឹងគុណ នឹងមាននិស្ស័យសុភាព គួរសមចំពោះអ្នកដែលជួយខ្លួនវិញ ។

សរុបសេចក្ដី.— និស្ស័យសុភាព គឺនិស្ស័យស្ងប់ស្ងៀមសុខស្រួល ត្រជាក់ត្រជុំ ។ និស្ស័យសុភាពនោះ ចាត់ថាជាលោហិតរបស់ជីវិត ដែលអាចបញ្ជូនរស្មីដល់ដួងវិញ្ញាណរបស់អ្នកដែលទ្រទ្រង់ទុក ទាំងរក្សាអ្នកដែលទ្រទ្រង់នោះ ឲ្យនៅគង់វង្សនឹងចំរើនរុងរឿងសមគួរដល់បំណងរបស់ជីវិត ។ កាលបើយើងមាននិស្ស័យស្ងប់ស្ងៀមត្រជាក់ត្រជុំហើយ និស្ស័យនេះ អាចជួយឲ្យយើងមានលក្ខណៈល្អបាននឹងធ្វើឲ្យអ្នកដទៃស្ងប់ស្ងៀមត្រជាក់ត្រជុំផង ប្រៀបដូចទឹកត្រជាក់ដែលយើងបរិភោគចូលទៅ អាចធ្វើឲ្យយើងរកកាយចិត្តនឹងធ្វើអ្នកដទៃទៀតដែលបានបរិភោគឲ្យត្រជាក់ដួងចិត្តផង ព្រមទាំងស្រោចស្រប់ពូជពង្សឲ្យត្រជាក់ចិត្តទៀត ។ បើយើងមាននិស្ស័យមិនសុភាពរៀបរយវិញ និស្ស័យនេះ នឹងធ្វើឲ្យយើងក្ដៅក្រហាយ ព្រមទាំងធ្វើឲ្យមនុស្សដទៃកើតក្ដៅក្រហាយក្រវល់ក្រវាយ មិនរៀបរយដែរ ប្រៀបដូចទឹកក្ដៅដែលយើងបរិភោគចូលទៅ អាចធ្វើឲ្យយើងក្ដៅនឹងធ្វើអ្នកដទៃទៀតដែលបានបរិភោគឲ្យក្ដៅដូចគ្នា ព្រមទាំងស្រោចទៅពង្សឲ្យក្ដៅទៀតផង ។

តាមពិត សេចក្ដីចេះដឹង អាចជួយយើងបាន ១៥ ភាគ លក្ខណៈនិស្ស័យសុភាព អាចជួយយើងបានដល់ទៅ ៨៥ ភាគ ។ ដូច្នេះ លោកអ្នក

ទើបគួរប្រើវេលា តាំងអំពីព្រឹកដល់ល្ងាច បណ្ដុះតែនិស្ស័យនេះ ត្រូវធ្វើឲ្យទាល់តែគេសរសើរថា "តាំងពីព្រឹកដល់ល្ងាច តាំងពីកើតដរាបដល់ស្លាប់ទៅជាខ្មោច, ការគន់ជីវិតនៅរបស់លោក អ្នកពេញទៅដោយនិស្ស័យសុភាព ទាំងកិរិយា ទាំងវាចា ទាំងចិត្តជានិច្ច" ។ សូម្បីក្នុងចំណែករួមគ្នាក៏ត្រូវធ្វើឲ្យទាល់តែគេសរសើរថា "តាំងពីព្រឹកដល់ល្ងាច តាំងពីកើតដល់ស្លាប់ទៅជាខ្មោច, ការគន់ជីវិតនៅនៃជាតិខ្មែរទាំងមូលពេញព្រៀបទៅដោយនិស្ស័យសុភាព ទាំងកាយ ទាំងវាចា ទាំងចិត្ត" ។ សូមកុំភ្លេចថា "ការរីករាយសើចហារបស់មនុស្សឃ្លើសឃ្លងក្នុងការបំបែកបំបាក់គេនោះ ជាការថោកទាបក្រៃលែងជាងការស្រែកថ្ងូររបស់មនុស្សនិស្ស័យសុភាពទៅទៀត" ។ "ឱម សុភាព មហាសុភាព ឆមោក្រាប ឥស្ភាសុ" នេះជាគាថា សម្រាប់ជប់ខ្លួនឲ្យក្លាយទៅជាមនុស្សមាននិស្ស័យសុភាពពេញទាំងត្រៃទ្វារ អញ្ជើញសែករឿយៗទៅ ។

ត្រូវសុភាព ពបសាសុខ ឲ្យផុតហៅ
គ្រាន់គួរហៅ ដែលកើតមក យកគម្រប់
ការសុភាព ជាទីតិ ល្អបំណាច់
ក្នុងផ្លូវច្បាប់ គ្មានរឿងអ្វី ក្រៃលែងជាង ៗ

## ឧបាយបណ្ដុះនិស្ស័យទី ៣

# និស្ស័យស្មោះត្រង់

ស្មោះត្រង់ជាអង្គមានខ្លឹមសារ
ស្មោះត្រង់ជាការជួយថែទាំ
ស្មោះត្រង់ជាបុណ្យគួរចាប់ពាំ
ស្មោះត្រង់នេះនាំឲ្យផុតភ័យ ។

លោកអ្នកសប្បុរសទាំងឡាយ ! សេចក្ដីស្មោះត្រង់ជាមកុដសិរីផ្ដល់ឲ្យនូវកេរ្តិ៍ឈ្មោះ ជាកំពូលនៃការជឿការស្ដាប់ការទុកចិត្តរបស់មនុស្សដទៃ ជាគុណធម៌ខាងដើមនឹងទីបំផុតនៃសេចក្ដីល្អទាំងឡាយ ជាមគ្គុទ្ទេសក៍ដ៏ប្រសើរដែលយើងគួររកទុក ដើម្បីនាំផ្លូវយើងទៅកាន់សេចក្ដីល្អដទៃៗទៀតតាមដែលត្រូវការ ។ អ្នកស្វែងរកសេចក្ដីសុខនិងកិត្តិយសគួរអប់រំសេចក្ដីស្មោះត្រង់នេះឲ្យជានិស្ស័យរបស់ខ្លួន ។ អ្នកណាបានពាក់មកុដ គឺ ការស្មោះត្រង់នេះហើយ អ្នកនោះឈ្មោះថាមានថ្វីដៃដែលជាទីជឿស្ដាប់ទុកចិត្តនៃមនុស្សដទៃ ប្រកាសកេរ្តិ៍ឈ្មោះរបស់ខ្លួនឲ្យគឹកកងខ្ទរទៅក្នុងលោកមិនឈប់ ។ មានសុភាសិតដែលចេញមកពីព្រះឱស្ឋនៃព្រះសម្មាសម្ពុទ្ធថា សច្ចំ វេ អមតា វាចា "សេចក្ដីស្មោះត្រង់ជារបស់មិនចេះស្លាប់" ។

សេចក្ដីស្មោះត្រង់ ជាធម៌គួរនិយាយរឿយៗ គួរប្រដៅញយៗ គួរនាំគ្នាអប់រំឲ្យញឹកញាប់ កុំបណ្ដែតបណ្ដោយ ព្រោះមនុស្សវៀចវេរនៅ

មានកន្លែងលោកនៅឡើយ ។ មើលចុះកន្លែងមហាវិទ្យាល័យ កន្លែងសាលារៀន កន្លែងគ្រឹះស្ថានតូចធំ សូម្បីត្រឹមតែកន្លែងផ្ទះរបស់មនុស្សស្លូមទាន ក៏គង់តែត្រូវសេចក្ដីវៀចវេរដឹកនាំឲ្យវង្វេងលេងកលមាយា លបបើកពេនល្បែង ដោយប្រើផ្លូវពីរដែរគឺវៀចនិងត្រង់លាយគ្នា ។ នៅមុខថ្វាយបង្គំ នៅក្រោយឡក, មុខត្រង់ ចិត្តវៀច ។ កាលនៅមុខសាច់ធ្វើចិត្តជាខ្លា នៅមុខព្រះធ្វើចិត្តជាមារ មិនគួរវង្វេងស្រឡាញ់មុខក្រឡៃមាសដូច្នេះសោះ ។ កាលដែលទិញក៏ប្រើលុយក្លែងក្លាយ កាលដែលលក់ក៏ឲ្យរបស់បន្លំ ជាអាជីវកិច្ចពុលថៃ ។ កន្លែងលោកនេះមិនមានអ្វីដែលគេបរិយាយមិនបាន មិនមានអ្វីដែលអ្នកប្រាជ្ញមិនដឹង មិនមានពាក្យខុសណាមួយដែលមនុស្សស្រវឹងមិននិយាយ និងមិនមានផ្លូវត្រង់ណាមួយដែលជាទីបំផុតនៃមនុស្សមេកលមាយាទេ ។

នេះជាកិរិយារបស់មនុស្សវៀច ដែលកាលហុចដៃពីចំងាយមកឃើញដួងភក្ត្រថា សំដែងឲ្យស្គាល់ថា “ស្រឡាញ់” គួរឲ្យជឿជាក់ គួរឲ្យអញ្ជើញពាក់ទាក់ឲ្យរួមទីអង្គុយជាមួយនឹងខ្លួនដែលជាមនុស្សកណ្ដាល ចូលមកឱបរួបរឹតដូចជាស្រឡាញ់ណាស់ គួរឲ្យក្ដើតក្ដើនចិត្ត មាត់សាកសួររៀងកវ៉ៃញយៗ ដោយសំដីដ៏ពីរោះ គួរឲ្យរីករាយ តែតាមពិតទៅគឺលាក់ពិសអាក្រក់ទុកខាងក្នុង សំដែងកំសួលចេញមកសុទ្ធតែទឹកឃ្មុំផ្អែមឆ្ងាញ់ ព្រោះជាមនុស្សជំនាញក្នុងកលមាយា គ្មាននិស្ស័យស្មោះ

ត្រង់ចំពោះនរណាពិតប្រាកដឡើយ មានតែនាំឲ្យចលាចលវឹកវរក្នុងកាលក្រោយម្យ៉ាង ។

នេះឯងជាដំណើរប្រព្រឹត្តរបស់គេ ដែលជាការប្រព្រឹត្តិលុបជ្រែងវៀចវេរត្រឡប់ត្រឡិនចេញក្រៅផ្លូវ ដូចយ៉ាងខ្ចីរបស់គេទៅ ធ្វើជាភ្លេចមិនយកមកសងគេ, ធ្វើរបស់គេឲ្យបែកធ្លាយឬខូចហើយ ធ្វើព្រងើយ, ទិញរបស់គេ ឃើញគេថែមលុយលើសមកហើយ ធ្វើជាមិនដឹង, ជិះរទេះរថយន្ត ឬ រថភ្លើង ឃើញអ្នកលក់មូលបត្រភ្លេចយកថ្លៃ ក៏ធ្វើព្រងើយ, អ្នកបង្គាប់បញ្ជាមេការ ឬនាយចៅហ្វាយមិននៅ ក៏មិនធ្វើការងារ បែរជាអង្គុយលេង ឬ ដេកលេង, ចូលចិត្តធ្វើការងារតែពេលដែលគេនៅចំពោះមុខ, កាលធ្វើការងារដែលយូរ មិនទាន់ដល់ពេល ក៏លបឈប់, ធ្វើការងារតែស្មើៗ កំពុងធ្វើក៏លបគេចវេះ, មាត់ប្រស័យទៅ ១ បែប ចិត្តគិតបំណងទៅមួយបែប ទាំងសេចក្ដីប្រព្រឹត្តក៏ល្អៀងទៅមួយបែបទៀត ។

ការធ្វើដូច្នេះ មនុស្សវៀចយល់ឃើញថា ជាការមានមុខមានមាត់ ឥតនឹកដល់សេចក្ដីស្មោះត្រង់បន្តិចបន្តួចសោះ ។ កាលបើមនុស្សវៀចនៅតែស្រឡាញ់សេចក្ដីវៀចវេរ ព្រោះយល់ឃើញដំណើរប្រព្រឹត្តបែបនោះថាជាការមានមុខមានមាត់ហើយ គប្បីជ្រាបថា ការមានមុខ ការលេចមុខរបស់មនុស្សវៀចនោះ គឺការឈានទៅកាន់រណ្ដៅកប់ខ្មោច ។

អ្នកដែលត្រូវមន្ទិលដឹកនាំឲ្យក្លាយទៅជាមនុស្សវៀច តែងវង្វេងភ្លេតភ្លើនក្នុងកម្មរបស់មនុស្សវៀច មិនយល់ឃើញដល់ការធ្វើខ្លួនឲ្យជាទី

ទុកចិត្ត ជាទីជឿ ជាទីរាប់អាន នៃមនុស្សដទៃជាសំខាន់ឡើយ ឃើញតែការវៀចវេរ ការទុច្ចរិត ការខុសសន្យា ការមិនសងបំណុល ការពោលកុហក ការប្រហើនគោងកាច និងការលលួងតែម្យ៉ាងថាជារបស់សំខាន់ និងឃើញថា បើជាប្រយោជន៍ចំពោះខ្លួនហើយ ក៏គួរធ្វើ ឬ សូម្បីការឆបោកបំបាត់លាក់លួចយក បើអស់អំណាចច្បាប់ គ្មាននរណាអាចនឹងធ្វើអ្វីខ្លួនបានហើយ ក៏ឃើញថាគួរយកដែរ នេះជាគំនិតអ្នកវៀចវេរ ។

សំរាប់អ្នកស្មោះត្រង់វិញ ឃើញថា ការធ្វើឲ្យគេជឿទុកចិត្តរាប់អាន ជាជីវិតដ៏ប្រសើរ ។ មនុស្សស្មោះត្រង់ តែងធ្វើត្រឹមត្រូវតាមធម៌ រក្សាពាក្យសន្យា មិនពោលកុហកបោកប្រាស ឬ លលួងនរណា តាំងនៅក្នុងសច្ចធម៌គ្រប់ត្រៃទ្វារ នឹងនិយាយអ្វី ក៏មានមនុស្សជឿមនុស្សស្តាប់ នឹងចរចាខ្ចីប្រាក់គេទាំងពាន់ ដោយមិនបាច់មានសំបុត្រសន្យា ឬ សាក្សី សូម្បីអ្នកនោះមិនមែនជាបងប្អូន ក៏អាចបានងាយ ៗ ព្រោះមនុស្សដទៃគេជឿជាក់ថា "យើងខ្ចីទៅហើយ កាលរកបាន មុខជាសងវិញ" ។ ហេតុនេះ ក្នុងធម្មនីតិ ទើបលោកពោលថា "បើសេចក្តីជឿនឹងសេចក្តីស្រឡាញ់គ្នានៅមាន សូម្បីប្រាក់ទាំងរយមិនចាំបាច់រាប់ក៏មាន តែបើមិនមានសេចក្តីជឿនឹងសេចក្តីស្រឡាញ់គ្នាវិញ សូម្បីប្រាក់ត្រឹមតែ ១ រៀល ក៏ត្រូវតែរាប់ខានពុំបាន" ។

ឧបាយសំរាប់បង្ក្រាបមនុស្សកោងនោះ បុគណាពោលថា នឹងបង្ក្រាបដោយការពោលប្រចុបប្រចែងក៏មិនបាន សូម្បីដោយការលើកតំកើងដោយការឱនលំទោន ដោយការយកចិត្តយកថ្លើម ដោយការធ្វើទោសនឹងដោយការបង្គាប់ ក៏មិនសម្រេចទាំងអស់ ។ ពិតមែន មនុស្សវៀចវេរ មានអ្នកប្រាជ្ញកត់ទោសទុកថា "មនុស្សវៀចវេរ ប្រតិបត្តិសេចក្តីស្មោះត្រង់បានដោយលំបាក មនុស្សស្មោះត្រង់ទើបប្រតិបត្តិបានដោយងាយ តែប្រតិបត្តិសេចក្តីវៀចវេរបានដោយកម្រ លុះតែអ្នកវៀចវេរ ទើបប្រតិបត្តិបានដោយងាយ" ទើបចាត់មនុស្សវៀចវេរ ថាជាមនុស្សអាក្រក់គ្រប់យ៉ាង ។

តែទោះបីដូច្នោះ ក៏គង់នៅមានឧបាយដែលសម្រាប់កែខៃបានដែរ ដូចជាប្រើព្រះរាជបញ្ញត្តិ ច្បាប់ទំលាប់ របៀបវិន័យបង្គាប់បញ្ជា នឹងប្រវេណីជាគ្រឿងអប់រំ នឹងជូនសេចក្តីខុស-ត្រូវឲ្យគេដឹងថា ធ្វើយ៉ាងណាជាមនុស្សវៀចវេរ ធ្វើយ៉ាងណាជាមនុស្សទៀងត្រង់ មានពលទាហានគង់ក្រវែលនាយជម្រូត ព្រមទាំងគ្រឿងសស្ត្រាវុធទុកសម្រាប់ការពារនឹងបង្ក្រាប ឲ្យមនុស្សវៀចវេរត្រឡប់ចិត្តជាមនុស្សស្មោះត្រង់ នឹងរក្សាមនុស្សស្មោះត្រង់ឲ្យនៅជាសុខសាន្ត តាំងពិធីសត្យាធិដ្ឋានឲ្យបញ្ចេញវចីសច្ចៈធ្វើសច្ចាប្រណិធានប្តេជ្ញាខ្លួន នឹងដាក់អាជ្ញា ឬ សន្យាល្មមដើម្បីឲ្យទៅជាមនុស្សស្មោះត្រង់ ។

(មានត)

# រឿងសាមកុក

## កណ្ឌទី ១២

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាជការផ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសត្ថានស្នេហាជាតិ ។

តាំងពីចូឆូនាំពលរេហ៍ចូលទៅក្នុងក្រុងឡូកអៀងតាមព្រះរាជតម្រាស់ តរៀងទៅដល់អួនសុតចៅហ្វាយស្រុកល្ហុំយុងលើកកងទ័ព ១០ ហ្មឺន ទៅវាយឡេវពីចៅហ្វាយស្រុកឈិជីវ ។

ស៊ុនហុកឆ្លើយថា វេលាកាលព្រះចៅជីវសេងអង់បានសោយរាជសម្បត្តិនោះ អាណាខេត្តកើតចលាចលខ្លាំងណាស់ ព្រះចៅជីវសេងអង់ទ្រង់ត្រាស់ឲ្យហៅជិនប៊ុនគុងទៅជួយធ្វើរាជការផ្ទាល់ព្រះអង្គ បណ្ដានាហ៊ុនគងស្រុកគ្រង ក៏នៅក្រោមបង្គាប់ជិនប៊ុនគុងទាំងអស់ អំណើះតមកជិនប៊ុនគុងបានសោយរាជសម្បត្តិដោយឯាយ គ្រានេះព្រះចៅហៀនតេឲ្យហៅលោកចូលទៅជួយធ្វើរាជការ ខ្ញុំយល់ថាជាការប្រពៃណាស់

គួរលោករហ័សចូលទៅតាមព្រះបង្គាប់ បើលោកបង្អង់ឲ្យយឺតយូរទៅទៀត អាណាខេត្តទាំងអស់ ណាដែលមានថ្វីដៃគេនឹងកៃខៃចូលទៅមុនលោកបាន ការពារការទាំងប៉ុន្មានក៏នឹងបានជាកម្មសិទ្ធដល់គេនោះ ឯខ្លួនលោកដែលមានឈ្មោះក៏នៅសោះទទេ ហេតុនេះគួរលោកត្រូវគិតតាមគំនិតរបស់ខ្ញុំបាទចូលទៅឲ្យឆាប់ ។

ចូទ្ធបានស្ដាប់ក៏យល់ឃើញត្រូវ ទើបចាត់ឲ្យទៅប្រុងប្រៀបរៀបសេនាទាហាន ប្រមូលបាន ៣០ មុឺនស្រេចហើយ លើកជាក្បួនទ័ពទៅដល់ពាក់កណ្ដាលផ្លូវ ទទួលមានបំរើសេះ នាំសេចក្ដីចូលទៅស្រុកក្រុងក្រាបបង្គំទូលព្រះចៅហៀនគេថា លីឈុយនឹងគុយគីលើកទ័ពទៅជិតដល់ស្រុកក្រុងឡូកអៀងហើយ ដោយគិតបំណងប៉ងនឹងវាយទំលាយចាប់យកព្រះចៅហៀនគេធ្វើអន្តរាយ ។ ព្រះចៅហៀនគេទ្រង់ព្រះតំរិះថា ទ័ពស្ភាននៅមិនទាន់បានរៀបគាក់តែងធ្វើបន្ទាយភាយបំរូង ជីកគូកំពែងជាមាំមួន នាហ្មឺននឹងបណ្ដារាស្ត្រក្នុងក្រុងក៏មានតិចណាស់ ឯបំរើដែលទាំសំបុត្រទៅហៅចូទ្ធក៏មិនឃើញត្រឡប់មកវិញ បើដូច្នេះអស់អ្នកទាំងឡាយនឹងយល់ឃើញដូចម្ដេច ដ្បិតបើលីឈុយនឹងគុយគីលើកទ័ពមកជិតហើយ ។

អៀវហង់ទិងហាន់សៀមយកសេចក្ដីក្រាបបង្គំទូលថា ដែលលីឈុយគុយគីលើកទ័ពមកនោះសូមកុំឲ្យព្រះអង្គទ្រង់ព្រះវិតក្កឡើយ ទូលព្រះបង្គំជាខ្ញុំនឹងសូមអាសាចេញទៅច្បាំងរាំងរក ជាទីស្នងព្រះគេជព្រះគុណត្រាតែអស់ជីវិត ។ តាំងសិនធ្វើយតបថា ក្នុងស្រុកឡូកអៀងនេះ

នៅមិនទាន់រៀបចំតាំងទីបន្ទាយជាមាំមួនសោះ ដែលអ្នកទាំង ២ នឹងកាប់រងធានាលើកសេនាទាហាន ចេញទៅតតាំងច្បាំងនឹងលីឈុយគុយគីនោះ យើងយល់ឃើញថា នឹងបរាជ័យចាញ់គេជាប្រាកដ យើងគិតនឹងអញ្ជើញព្រះចៅហៀនតេស្តេចរត់ចេញពីទីនេះ ទៅនៅខាងអាណាខេត្តទិសបូព៌ាវិញ ទើបនឹងបានរួចអំពីភ័យ ។

ព្រះចៅហៀនតេទ្រង់យល់ឃើញផង តាំងស៊ុននឹងនាហ៊ានមុខមន្ត្រីទាំងពួងក៏រៀបអញ្ជើញស្តេច ព្រមទាំងព្រះអគ្គមហេសីស្រីស្នំក្រមការឡើងគង់ព្រះរាជរថចេញចាកក្រុងឡូកអៀង យាងតាមផ្លូវទៅប្រហែលចម្ងាយ ២០ សិន (៨០០ គ.ម.) ក៏ក្រឡេកឃើញកងទ័ពតាន់តាប់លើករន្ទាន់ចូលមកពីទិសបូព៌ា សូរទាហានហ៊ោកញ្ជ្រៀវគឹកកងរំពងទាំងផែនពសុធា ។ ឯព្រះរាជអាជ្ញាដែលកាន់ព្រះតម្រាស់ក៏ជិះសេះចូលមកមុនដល់ចំពោះមុខព្រះទីនាំងរថហើយ យកសេចក្តីក្រាបបង្គំទូលថា ឥឡូវនេះចូចូលើកសេនាយោធាមកដល់កណ្តាលផ្លូវហើយ ឮកិត្តិស័ព្ទថាលីឈុយគុយគីលើកកងទ័ពមកនឹងធ្វើអន្តរាយដល់ព្រះអង្គ កងក្រុងឡូក-អៀង, ចូចូក៏ប្រើហាហូទុន ខៅជូ តៀនអ៊ុយលើកទាហាន ៥ ម៉ឺនដែកចូលមក ដើម្បីនឹងបានជួយការពាររក្សាព្រះអង្គ ។ ព្រះចៅហៀនតេបានទ្រង់ព្រះសណ្តាប់ ក៏មានព្រះទ័យត្រេកអរពន់ប្រមាណ ។ ទទួលហាហូទុន ខៅជូ នឹងតៀនអ៊ុយចូលមកក្រាបថ្វាយបង្គំកងទ័ពនោះ ។

មានបំរើសេះចូលមកក្រាបទូលទៀតថា ឃើញកងទ័ពលើកមកពីទិសបូព៌ាក្រោយបណ្តាយដល់មកទៀតហើយ ។ ព្រះចៅហៀនគេត្រាស់ប្រើហៃហ្វូទុនទៅពិនិត្យមើលឲ្យច្បាស់ ។ ហៃហ្វូទុនក៏បរសេះចេញទៅជួបនឹងហេហាង លីតៀន, អាក់ជិនលើកទាហានមក ក៏នាំនាយទាហានទាំង ៣ នាក់នោះចូលទៅក្រាបបង្គំគាល់ ហើយទូលថា ចូឆូប្រើហៃហ្វូទុន ទៅជួបនឹងគៀនអ៊ុយលើកទ័ពមកមុននោះ កែងមិនជួនការបាន ជាប្រើទូលព្រះបង្គំជាខ្ញុំទាំង ៣ នាក់ ឲ្យលើកទាហានមកជួយថែមទៀត ដើម្បីនឹងចាប់អាសត្រូវសម្លាប់ចេញឲ្យបាន ។ ព្រះចៅហៀនគេទ្រង់ព្រះសណ្តាប់ ក៏ចាប់ព្រះរាជហឫទ័យណាស់ត្រាស់ថា ចូឆូនោះពេញជាមនុស្សមានសតិបញ្ញាឈ្លៀវឆ្លាត ហើយត្រង់សុចរិតពិតល្អដល់យើង គួរនឹងដំកើងលើកឲ្យធ្វើជាសេនាបតីធំសម្រេចរាជការតទៅ ។

ខណៈនោះ មានបំរើសេះពីទិសបស្ចិមនាំដំណឹងចូលមកក្រាបបង្គំទូលព្រះចៅហៀនគេទៀតថា ទ័ពលីឈុយគុយគីលើកចូលមកដល់ដែនស្រុកឡកអៀងហើយ ឥឡូវនេះ គ្មានអ្នកឯណានឹងទប់ទល់សោះ ។ ព្រះចៅហៀនគេត្រាស់សួរហៃហ្វូទុនថា ដែលលីឈុយគុយគីលើកទ័ពមកដូច្នេះ អ្នកនឹងគិតប្រការម្តេច ។ ហៃហ្វូទុនក្រាបបង្គំទូលថា "សូមព្រះអង្គទ្រង់កុំព្រួយព្រះរាជហឫទ័យភ័យនឹងទ័ពលីឈុយគុយគីឡើយ ទុកធុរៈទូលព្រះបង្គំជាខ្ញុំ ហើយនឹងសេនាទាំងពួង ជាកងទ័ពមុខចូឆូ ទទួលយក

អាសាទៅដាក់សង្កត់ពួកអាចោរកំណាចទាំងនោះ ឲ្យរៀបដូចផ្ទៃផែនដី" ថាហើយក៏ក្រាបថ្វាយបង្គំលាចេញទៅចាត់ចែងសេនាទាហាន ហៃហ៊ូទុនជាកងស្តាំ តោហានជាកងឆ្វេងហើយលើកចេញទៅ លុះទៅដល់ប្រទល់កងទ័ព ក៏បរពលចូលប្រកាប់គ្នាពារទំលាយដោយកំលាំងអាវុធនឹងសេនាទាហាន ។ ពលលីឈ្មុយគុយតីទាំងប៉ុន្មានក៏សឹងតែរបួសពិការស្លាប់ត្រៀបត្រានឹងគណនាពុំបាន លីឈ្មុយគុយតីទប់ពុំបានក៏នាំទាហានដែលសល់នោះស្ទុះរត់រួចទៅ ។ ហៃហ៊ូទុននឹងតោហានក៏លើកកងទ័ពដេញសង្កួញទៅទៀត ឃើញថាលីឈ្មុយគុយតីរត់ព្រាត់ព្រាយឆ្ងាយទៅហើយ ក៏លើកកងទ័ពត្រឡប់មកវិញ ហើយអញ្ជើញព្រះចៅហៀនតេ ស្តេចយាងចូលទៅក្នុងក្រុងឡកអៀងដូចដើម រួចចាត់ចែកបំបែកកងទ័ពឲ្យឡោមព័ទ្ធប្រយ័ត្នរក្សាទីក្រុងជុំវិញ ។

លំដាប់នោះ ចូចូលើកកងទ័ពធំមកដល់ ហើយចូលទៅលុតជង្គង់ក្រាបបង្គំគាល់ព្រះចៅហៀនតេដោយគោរព ។ ព្រះចៅហៀនតេទតឃើញមុខចូចូក៏ទ្រង់សោមនស្សស្មោះសរ មានព្រះរាជឱង្ការត្រាស់ថា អ្នកកុំគប្បីលុតជង្គង់ក្រាបបង្គំគាល់យើងដូច្នេះឡើយ ចូរអង្គុយឈរដោយប្រក្រតីចុះ ។ ចូចូក៏ធ្វើតាមព្រះតម្រាស់ហើយទូលថា ដែលព្រះអង្គជប់លៀងទូលព្រះបង្គំជាខ្ញុំមកតាំងពីដើមនោះ ព្រះតេជព្រះគុណមិនមានទីបំផុត ទូលព្រះបង្គំជាខ្ញុំ តាំងចិត្តគិតនឹងធ្វើរាជការថ្វាយធួនព្រះតេជព្រះគុណ

នៅជាដរាបមិនមានក្លេបសោះ គ្រានេះលីឈុយគុយគីមានសេចក្ដីប្រទូស-រាយដល់ព្រះអង្គនេះ សូមកុំឲ្យទ្រង់បរិវិតក្កៈឡើយ ទុកជាទូលព្រះបង្គំជាខ្ញុំនឹងត្រិះរិះរកឧបាយសម្លាប់លីឈុយគុយគីបញ្ចេញឲ្យបាន ។ ព្រះចៅហៀនតេ ទ្រង់មានព្រះរាជហឫទ័យបីតិប្រាមោជពន់ប្រមាណ ទើបតាំងឲ្យបូចូឡើងទីជាសេនាបតីធំសំរេចរាជការ តាំងព្រះកាណព្រះនេត្រទូទាំងព្រះរាជអាណាខេត្តក្នុងក្រៅគ្រប់ក្រសួង ។

ឯលីឈុយគុយគីដែលបែកទ័ពទៅនោះ ក៏តាំងតែហ៊ឹកហាត់សេនាទាហានបានជាច្រើន លុះដឹងថាបូចូមកដល់ហើយ ទើបប្រឹក្សាគ្នាថា ឥឡូវនេះទាហានបូចូកំពុងខ្សោយកំឡាំងណាស់ ហេតុនេះគួរយើងប្រញាបលើកកងទ័ពទៅខ្ទប់វាយកុំឲ្យដឹងខ្លួនក៏នឹងបែកៈដាយងាយ ។ កាសៀងង៉ើយថា លោកគិតដូច្នោះមិនស្រួលទេ ព្រោះបូចូនោះមានសេនាឯកនឹងទាហានច្រើនណាស់ លើសនឹងគណនា ឯសេនាទាហានខាងយើងស្ដើងស្ដួចពេក បើទុកជានឹងលើកទៅប្រឹងវាយបំបែកដូចម្ដេចក៏ពុំបាន ឧបមាដូចសត្វតិរច្ឆានតូចៗ ទៅទទួលប្រយុទ្ធនឹងខ្លា គំនិតខ្ញុំយល់ថាត្រូវឲ្យលោកចាត់បំរើចូលទៅសុំទោសបូចូវិញស្រួលជាង ហើយសុំផ្ញើរូបរាងជ្រកកោន ឲ្យបានបូចូមានមេត្តាដល់លោកទាំង ២ ។ លីឈុយគុយគីបានស្ដាប់ពាក្យកាសៀងនិយាយដូច្នោះ ក៏ពុះពោរក្រដូវខឹងនឹងកា-សៀងណាស់យកដៃទះតប់តុហើយថា "យើងកំពុងគិតធ្វើសង្គ្រាមនឹង

ចូចូជាម៉ាមួន ហេតុម្តេចខ្លួនហ៊ានមកនិយាយបន្ទាបបន្ថោកយើងដូច្នេះ ដែលខ្លួននិយាយយ៉ាងនេះ នឹងចង់ឲ្យសេនាទាហានរបស់យើងរញ្ញាក្ខ?» ថាហើយក៏កន្ទ្រាក់ក្រើបឡើងការ៉ាន់ គិតនឹងស្ទុះទៅកាប់សម្លាប់កាសៀង ក្នុងខណៈនោះ ៗ បណ្ដាទាហានក៏ស្ទុះទៅពាំងប្រឹងជួយសុំទោសបាន ៗ កាសៀងទោមនស្សតូចចិត្តពេកណាស់ លុះវេលាយប់ក៏ឡើងសេះជិះតែទៅនៅស្រុកទេសរបស់ខ្លួន ៗ លុះព្រឹកឡើងលីឈុយគុយគីផុំពលយោធាជាក្បួនទ័ព បង្គាប់ប្រើឲ្យលីសៀមនឹងលីប៉េកជានាយទ័ពស្រួចលើកទៅច្បាំងនឹងចូចូ ៗ

ខណៈនោះ ចូចូបាត់ប្រើ ទៅជូ គៀនអ៊ុយ ហោយិន ឲ្យលើកទាហានសេះ ៣០០ ចេញទៅតយុទ្ធនឹងកងទ័ពលីឈុយគុយគី តាំងតែចាក់កាប់សម្លាប់កងទ័ពនោះស្លាប់វិនាសជាច្រើន ៗ ឯលីសៀមនឹងលី-ប៉េកជាសេនាក៏ចេញមកតនឹងទៅជូមិនទាន់បាន ១ ក្បួន ទៅជូ ក៏ចាក់នឹងលំពែងត្រូវលីសៀមធ្លាក់ពីលើសេះស្លាប់ ៗ ឯលីប៉េកនោះគ្រាន់តែក្រឡេកឃើញទៅជូគ្រាមក៏តក់ស្លុតភ្ញាក់ធ្លាក់ពីលើសេះទោក ទៅជូ ស្ទុះទៅចាក់នឹងខ្លួនស្លាប់ទៅទៀត ហើយកាត់យកក្បាលលីសៀមនឹងលីប៉េកនាំទៅឲ្យចូចូៗ មានសេចក្ដីត្រេកអរណាស់ យកដៃទះអង្អែលខ្នងទៅជូ ហើយសរសើរថា មានថ្វីដៃខ្លាំងពូកែសមគួរជាសេនាឯក ៗ

ចូចូក៏ប្រើហែហួទុនជាមេកងទ័ពស្រួច ហោយ៉ិនជាមេកងប៉ែកស្ដាំ ខ្លួនចូចូឯងជាមេកងទ័ពហ្លួង លើកជាស្លាបក្អែកដែកចូលទៅច្បាំងនឹងកងទ័ពលីឈុយគុយគី សម្លាប់រេហ៍ពលលីឈុយគុយគីស្លាប់ច្រើនណាស់ លីឈុយគុយគីក៏បែកទ័ពរត់ទៅ ចូចូបរពលទាំងក្នុងក្រៅដេញតាមទៅទៀត រើសបានគ្រឿងសស្ត្រាវុធជាច្រើនណាស់ នៅតែលីឈុយនឹងគុយគីទាំង ២ នាក់ នាំគ្នារត់ទៅជ្រកពួននៅក្នុងកៀនភ្នំ ១ ចូចូក៏លើកទ័ពថយត្រឡប់មកវិញ ។

ឯអៀវហងជឹងថា ចូចូវាយទំលាយទ័ពលីឈុយគុយគីបែកហើយ ក៏ប្រឹក្សានឹងហាន់សៀមថា ចូចូធ្វើសង្គ្រាមគ្រានេះធំពន្លឹកពេកណាស់ យូរទៅពងការទាំងអស់ក្នុងស្រុកក្រុងនឹងនៅក្នុងកណ្ដាប់ដៃចូចូតែម្ដង យើងទាំង ២ ក៏នឹងនៅក្រោមអំណាចចូចូ បើដូច្នេះយើងត្រូវតែគិតកលឧបាយលើកស្ម័គ្រប័ក្សពួករបស់យើងទាំងឡាយ ទៅចាប់លីឈុយគុយគីសម្លាប់ចោល ហើយរត់យកខ្លួនទៅជ្រកពួនឯស្រុកតែលៀងវិញ ។ ហាន់សៀមឃើញត្រូវផង ទើបនាំគ្នាចូលទៅក្រាបបង្គំគាល់ព្រះចៅហៀនតេទូលថា ដែលចូចូលើកទ័ពទៅសម្លាប់រេហ៍ពលលីឈុយគុយគីបែកខ្ចាត់ខ្ចាយទៅហើយនោះ ទូលព្រះបង្គំជាខ្ញុំសូមចេញយកអាសាលើកគ្នាតាមទៅទៀត បើជួបប្រទះលីឈុយគុយគី នៅទីណានឹងចាប់ខ្លួនវាសម្លាប់ចេញឲ្យបាន ។ ព្រះចៅហៀនតេក៏ទ្រង់យល់ព្រម អៀវហងនឹងហាន់សៀម ក៏ក្រាបបង្គំលាម្នីម្នារៀបប្រមូលស្ម័គ្រប័ក្សពួក លើកចេញពីទីក្រុងឡកអៀងទៅ ។

(មានត)

# រឿងអារក្សថ្លែងរឿងថ្លៃថ្លា

## លោកសាង-សារ៉ាត លេខានុការ ក្រសួងហិរញ្ញវត្ថុ

### ប្រែពីភាសាបារាំងមកជាខ្មែរ

(តមក)

## រឿងទី ៤

នៅក្នុងក្រុង កាញ្ចនបុរៈ (Kanchanpur ប្រែថាក្រុងមាស) មានអ្នកជំនួញម្នាក់ឈ្មោះ សាគរទត្ត (Sâgardatt ប្រែថា កើតដោយសារសមុទ្រ) ។ អ្នកជំនួញនេះ បានរៀបការកូនប្រុសឈ្មោះ សិរីទត្ត (Ciridatt ប្រែថា កើតមកអំពីទ្រព្យ) ជាមួយនឹងនាងជយសិរី (Jayacri) បុត្រីរបស់អ្នកជំនួញម្នាក់ទៀតឈ្មោះសោមទត្ត (Sòmdatt) ដែលស្ថិតនៅ ក្នុងទីក្រុងមួយទៀតជិតក្រុងជយសិរីបុរៈ (Jayacripur) ។ ប៉ុន្តែគ្រាន់តែការហើយនាងជយសិរី នៅជាមួយនឹងឪពុកម្តាយរបស់នាង, ចំណែកប្តីរបស់នាង បានទៅស្រុកមួយទៀត ដើម្បីធ្វើជំនួញ ។ ជនទាំង ២ ឥតបានរួមដំណេកគ្នាទេ ។

ចំនួន ១២ ឆ្នាំកន្លងទៅ បុរសជួញបានចំណេញចំណូលច្រើន ។ ឯនាងជយសិរីជាភរិយា ដែលគាត់បានរៀបការពេញច្បាប់ ថ្ងៃមួយនាងនិយាយទៅកាន់ស្រីជំនិតរបស់នាងថា "ឱបង! យុវចរិយារបស់ប្អូនកន្លងមក ឯរូបប្អូនមិនទាន់ស្គាល់តម្រេកណាមួយរបស់លោកិយសោះឡើយ" ។

ស្រីសហជីវិនរបស់នាង ឆ្លើយវិញថា "ចូរអ្នកនាងកាន់ចិត្តអត់ទ្រាំសិនទៅ បើទេវតាលោកជួយ គង់តែប្ដីរបស់អ្នកនាងត្រឡប់មកឧបត្ថម្ភសោបអ្នកនាងវិញទេ" ។

ប៉ុន្តែនាងមិនបានឡើងទៅលើផ្ទះ ហើយៈបាលគ្រាប់ភ្នែកតាមបង្អួចស្រាប់តែឆ្ងល់ដោយបានឃើញបុរសម្នាក់ដើរចូលមក ។ កាលបុរសនោះមកដល់ជិតនាងក៏ងើបក្បាល ។ ភ្នែកជនទាំងពីរខ្វែងគ្នា ។ ជនទាំងពីរចាប់ចិត្តស្នេហានឹងគ្នាទៅវិញទៅមក ។ នាងបានបង្គាប់ឲ្យស្រីបំរើទៅនាំបុរសនោះចូលមក ។ ស្រីបំរើក៏ទៅជិតបុរសហើយនិយាយថា "កូនស្រីរបស់លោកសោមទត្ត ឲ្យខ្ញុំមកអញ្ជើញលោកទៅ ដ្បិតនាងចង់ជួបនឹងលោកតែម្នាក់ឯង សូមលោកអញ្ជើញទៅទីកន្លែងរបស់ខ្ញុំ" ដូច្នេះរួច នាងបង្ហាញកន្លែងផ្ទះរបស់នាង ។ បុរសឆ្លើយទៅវិញថា ខ្ញុំនឹងទៅក្នុងពេលយប់នោះ ។ កាលណានាងស្ដាប់រឿង (ការកំណត់ពេល) នេះទៅប្រាប់នាងជយសិរីហើយ នាងជយសិរីនិយាយថា "ត្រឡប់ទៅផ្ទះបងឯងវិញចុះ កាលណាគេមក ចូរបងប្រាប់ខ្ញុំឲ្យដឹងមុន រួចខ្ញុំនឹងចេញពីផ្ទះទៅដោយឥតញញើតឡើយ" ។

លុះបានឮពាក្យអស់នោះហើយ នាងស្ទុំក៏ទៅផ្ទះរបស់នាងវិញ ហើយអង្គុយនៅលើមាត់ទ្វារ រង់ចាំមើលផ្លូវ ។ ក្នុងពេលនោះ បុរសមកដល់ ។ នាងស្ទុំនោះ លុះឲ្យបុរសអង្គុយនៅមាត់ទ្វារហើយ និយាយថា "ចូរ

លោកអង្គុយនៅទីនេះចុះ ខ្ញុំទឹងទៅជំរាបនាងជយសិរី" ដូច្នេះហើយក៏ទៅប្រាប់នាងថា "មិត្តរបស់អ្នកនាងមកដល់ហើយ" ។

នាងជយសិរីនិយាយថា: "ចាំបន្តិចទៅ, កាលណាជនក្នុងផ្ទះដេកលក់អស់ ទើបខ្ញុំទៅ" ។ មួយសន្ទុះក្រោយមក នាងទៅដល់ ។ ជនទាំងពីរក៏បានជួបគ្នាក្នុងផ្ទះនោះ ដោយរីករាយ ។

ម៉ោងបួនមុនភ្លឺ នាងក្រោកឡើងរួចត្រឡប់ទៅផ្ទះរបស់នាងវិញ ទៅទំរេតយ៉ាងស្រួល ហើយដេកលក់ទៅ ។ ដល់ព្រលឹមឡើង បុរសត្រឡប់ទៅផ្ទះរបស់ខ្លួនវិញដែរ ។

ច្រើនថ្ងៃកន្លងមក ជនទាំងពីរនេះតែងប្រព្រឹត្តយ៉ាងនេះឯង ។ ក្រោយមក ប្ដីរបស់នាងត្រឡប់មកពីប្រទេសដទៃ ហើយចូលមកក្នុងផ្ទះ ផ្ទុកគ្រឿងរបស់ខ្លួនវិញ ។ កាលណាមាងឃើញ នាងគិតក្នុងចិត្ត រួចនិយាយទៅកាន់នាងស្នំថា: "ខ្ញុំចង្អៀតចិត្តណាស់ តើឲ្យខ្ញុំនិយាយយ៉ាងណា? តើឲ្យខ្ញុំទៅណា? ខ្ញុំលែងដេក លែងផឹក លែងស៊ី អស់ហើយ ធាតុក្ដៅនិងធាតុត្រជាក់ គ្មានផលអ្វីមកលើខ្ញុំសោះ" ។ គឺនាងនិយាយអំពីទុក្ខគានតឹងចិត្តប្រាប់នាងស្នំរបស់នាង ។

ថ្ងៃកន្លងទៅទាំងល្ងាចទាំងអាក្រក់, ប៉ុន្តែដល់ពេលយប់ កាលណាសិរីទត្ត បរិភោគអាហាររួច ម្ដាយក្មេករបស់គាត់ ដែលបានឲ្យគេរៀបចំគ្រែមួយនៅក្នុងគ្រឹស្ថានមួយដាច់ពីគេនោះ បានឲ្យសិរីទត្តទៅសម្រាក

កាយ រួចបង្គាប់កូនស្រីឲ្យទៅកម្ដរផង ។ ប៉ុន្តែនាងចង់ចំពើមទៅរកម្ដាយ ឥតកំរើក ។ ម្ដាយរបស់នាងក៏កំហែងហើយបង្គាប់នាងម្ដងទៀត ជាគំរប់ពីរដងឲ្យទៅជិតប្ដីនាង ។ ដោយពុំអាចរឹងទទឹង នាងក៏ទទួលបង្គាប់ ហើយទៅដេកលើគ្រែដោយឆាកក្បាលចេញ ។ នាងមានទុក្ខព្រួយកាន់តែខ្លាំងឡើងៗ ក្នុងពេលដែលបុរសថ្នាក់ថ្នមនាង ។ កាលណាបុរសបង្ហាញអាវទាំងឡាយនិងគ្រឿងមាសពេជ្រគ្រប់មុខ ដែលខ្លួនបានយកពីគ្រប់ភូមិស្រុកមកនោះ ហើយកាលណាបុរសឲ្យប្រដាប់តាំងអស់ ទៅនាងពាក់នោះ នាងរឹងរឹតតែខឹងឡើង ចង់ចំពើមបែរខ្នងដាក់ប្ដី ។ បុរសក៏អស់សង្ឃឹមមិនដឹងធ្វើយ៉ាងណាឲ្យនាងសប្បាយចិត្ត ហើយដោយអស់កំលាំងផង ក៏ដេកលក់ទៅ ។ ចំណែកខាងនាងវិញ ដោយសារគំនិតដែលគិតដល់សហាយធ្វើឲ្យនាងដេកពុំលក់ឡើយ ។

កាលណានាងឃើញថា សិរីទត្តដេកលក់ស្កប់ស្កល់ហើយ, នាងក៏ក្រោកឡើងយ៉ាងថ្នមៗ ដោយទុកឲ្យបុរសដេកលក់ ដើរតម្រង់ឥតញញើតទាំងកណ្ដាលរាត្រីជ្រៅ ទៅកាន់ទីផ្ទះមិត្តរបស់នាង ។ ចោរមួយលុះឃើញនាងទៅតាមផ្លូវដូច្នោះ នឹកឆ្ងល់ក្នុងចិត្តថា តើស្ត្រីដែលមានពាក់គ្រឿងមាសពេជ្រនេះ ទៅណាតែឯងកណ្ដាលយប់ដូច្នេះ? ។ ឯនាងក៏ដើរទៅដល់ផ្ទះមិត្តរបស់នាងនោះ ដោយលំបាកខ្លះស្រួលខ្លះតាមធម្មតា ប៉ុន្តែប្រុសជាសហាយរបស់នាងដួលស្លាប់នៅលើដីដោយពស់

ចឹក ៗ នាងនឹកស្មានថាដេកលក់, នាងហេតុតែមានទុក្ខព្រួយ ព្រោះឃ្លាតអំពីសហាយនេះ ក៏បានឱបរូបបុរសយ៉ាងស្និទ្ធពេញដៃ ហើយអង្អែលបុរសនោះថែមទៀត ៗ គង់ពេលនោះ ទេវតាពិនិត្យមើលរឿងនេះពីចម្ងាយ ៗ មានបិសាចៈលមួយ អង្គុយនៅលើដើមជ្រៃ ក៏មើលរឿងនេះដែរ ៗ ស្រាប់តែបិសាចនេះ មានគំនិតចង់ចូលក្នុងរូបខ្មោចសហាយរបស់នាងនេះ ដើម្បីត្រេកត្រអែកស្នេហាអំពីនាង ៗ លុះគិតដូច្នោះ ក៏ចូលទៅក្នុងរូបខ្មោចមួយរំពេច ហើយធ្វើអាកប្បកិរិយាស្នេហាជាមួយនាង រួចបានខាំច្រមុះនាងនឹងធ្មេញ ហើយឡើងទៅលើព្រឹក្សារបស់វាវិញទៅ ៗ ទេវតាមើលឃើញអស់ ៗ ឯស្ត្រីអកតញ្ញូឈាមសស្រាក់ត្រឡប់ទៅផិតនាងស្នំ ហើយនិយាយរឿងប្រាប់ ៗ ស្រីសហជីវិនរបស់នាងនិយាយថា: "ចូរអ្នកនាងត្រឡប់យ៉ាងឆាប់ទៅជិតសិរីទត្តជាប្តីរបស់អ្នកនាងវិញ ឲ្យបានមុនគាត់ភ្ញាក់ពីដេក, រួចអ្នកនាង ស្រែកយំខាំធ្មេញ ហើយបើអ្នកណាសួរ ឆ្លើយទៅវិញភ្លាមថា ប្តីរបស់នាងខាំច្រមុះអ្នកនាង" ៗ

នាងក៏ទៅវិញ តាមពាក្យមិត្តរបស់នាងរួចតាំងយំនឹងខាំធ្មេញ ៗ ដោយសូរសំរែកនេះ ក្រុមញាតិទាំងអស់ក៏មកដល់ បានភ្ញាក់គ្រប់គ្នា កាលឃើញនាងអង្គុយដាច់ច្រមុះបាត់ដូច្នោះ ក៏ខឹងទាំងអស់គ្នានិយាយឡើងថា "អាចង្រៃ! អាចិត្តប្រេត! អាឯងមិនខ្មាសគេទេឬ? គ្នាគ្មានទោសហេតុអ្វីសោះ ហេតុដូចម្តេចបានជាអាឯង ខាំច្រមុះវា?" ៗ

សិរីទត្ត ដោយឃើញរឿងរ៉ាវចំឡែកនេះទើបគិតយូរបន្តិចទៅ នឹកម្នាក់ឯងថា: «គេមិនត្រូវទុកចិត្តមនុស្សខ្វរអាក្រក់, សត្វពស់វែក, មនុស្សដែលមានកាន់អាវុធ ឬស្រីណាមួយទេ, រួចគេត្រូវខ្លាចអំពើរបស់ស្រី, តើត្រង់ណាដែលកវីបណ្ឌិតមិនអាចរៀនបាន, តើត្រង់ណាដែលអ្នកប្រាជ្ញមើលមិនឃើញ, តើមានរបស់អ្វីដែលមនុស្សស្រវឹងពុំអាចនិយាយបាន, ហើយតើអ្វីខ្លះ ដែលមនុស្សស្រីពុំអាចធ្វើបាន. ចំណាំដល់ទៅទេវតាម៉េចគង់មិនស្គាល់កំហុសរបស់សត្វសេះ, ពងពៅរបស់ពពក, កិច្ចកលរបស់ស្រី នឹងវាសនាល្អរបស់មនុស្សប្រុស ចុះទម្រាំមនុស្សលោកគេនឹងអាចអះអាងថាស្គាល់ម្ដេចកើត ...» ។

ក្នុងពេលនោះ ឪពុករបស់នាងបានទៅប្ដឹងភ្នាក់ងាររកងក្រវែលៗ មកដល់ភ្លាម ចាប់សិរីទត្តចងហើយនាំខ្លួនទៅ ។ លោកមេកងក្រវែលទៅទូលស្ដេច ។ ស្ដេចទ្រង់បានហៅសិរីទត្តមកហើយ មានព្រះឱង្ការសួរដំណើរដើមទង ។ សិរីទត្តឆ្លើយថា: «ទូលព្រះបង្គំមិនដឹងការណ៍អ្វីសោះ» ។ ស្ដេចទ្រង់មានព្រះបន្ទូលហៅកូនស្រីរបស់នាយជំនួញមកទ្រង់បានសាកសួរ ។ នាងឆ្លើយទូលតបថា «សូមព្រះករុណាដកល់លើត្បូងទ្រង់ជ្រាប មិនចាំព្រះអង្គសាកសួរទូលព្រះបង្គំទេ ព្រោះព្រះអង្គទតឃើញជាក់ស្ដែងនឹងព្រះនេត្រស្រាប់» ។ ស្ដេចក៏ទ្រង់ងាកទៅរកសិរីទត្ត ហើយមានព្រះរាជឱង្ការថា «ឯងត្រូវមានទោស» ។

សរីទត្តទូលតបថា: "សូមព្រះអង្គធ្វើតាមដែលទ្រង់យល់ឃើញថាត្រូវគន្លងយុត្តិធម៌ចុះ" ។ ព្រះរាជាទ្រង់បង្គាប់ថា: "ចូរនាំខ្លួនសរីទត្តនេះទៅ ហើយយកទៅធ្វើទោសចុះ" ។

ជនទាំងឡាយលុះបានទទួលបង្គាប់ហើយ ក៏នាំសរីទត្តទៅដើម្បីយកទៅធ្វើទោស ប៉ុន្តែចោរដែលជាសាក្សីនៃរឿងអស់នេះបានចូលមកដល់ ។ កាលណា ចោរនេះ ឃើញថាគេមុខជាធ្វើទោសបុរសប្រាកដហើយក៏សុំខ្លួនរកយុត្តិធម៌ ។ ស្តេចទ្រង់ឲ្យហៅចោរមក ហើយទ្រង់សាកសួរចោរនេះ ។ ចោរឆ្លើយថា: "សូមទ្រង់ដកលំលើត្បូងក្រាប! ទូលព្រះបង្គំជាចោរ ឯបុរសនេះគ្មានទោសអ្វីទេ រូបឈាមរបស់គាត់ដែលត្រូវហូរនោះមិនសមសោះ ព្រះអង្គគ្មានកាត់សេចក្តីតាមយុត្តិធម៌សោះ" ។ ព្រះរាជាទ្រង់ឲ្យហៅសរីទត្តមក ហើយសួរចោរថា: "ចូរឯងនិយាយតាមសម្បជញ្ញៈរបស់ឯង រួចចូរឯងប្រាប់ការពិតមកយើងអំពីរឿងនេះ" ។ ចោរក៏និទានរឿងហូរហែគ្មានបាត់ខ្វែងណាឡើយ ។ ឯស្តេចក៏ទ្រង់ឲ្យទាសាទៅមើលការណ៍ ទាសាក៏យកប្រមុះដែលបានទាញចេញអំពីមាត់ខ្មោចមក ។ លុះទ្រង់ទតឃើញដូច្នោះ ស្តេចទើបយល់ថាសរីទត្តគ្មានទោសហេតុអ្វីទេ ហើយចោរនេះនិយាយការពិតប្រាកដ ។ ចោរទូលព្រះមហាក្សត្រថា: "សូមទ្រង់ដកលំលើត្បូងក្រាបករណីយកិច្ចសម្រាប់ស្តេចគ្រងផែនដីទាំងអស់ គឺត្រូវស្រឡាញ់អំពើល្អ ហើយធ្វើទោសមនុស្សកំណាច" ។

លុះនិយាយដូច្នោះហើយ សេកជូរ៉ាមាន (Churaman) ក៏ឈប់ដើម្បីនិយាយការទៅព្រះមហាក្សត្រិយ៍ថា: "មហារាជ! នោះហើយគឺកិរិយាអាក្រក់ ដែលគេប្រទះឃើញក្នុងមនុស្សស្រី" រួចសេកនិយាយតទៅទៀតថា: "ស្ដេចនោះក៏ទ្រង់បង្គាប់ឲ្យគេលាបមុខស្រីនោះ ដោយពណ៌ខ្មៅ រួចបង្គាប់ឲ្យគេកោរសក់នាងនោះទៀត លុះឲ្យនាងនោះជិះលើសត្វលាមួយហើយ ស្ដេចទ្រង់ឲ្យបណ្ដើរអាក្រាសតាមទីក្រុង រួចឲ្យនាំនាងនោះទៅៗ ។ កាលណាទ្រង់ប្រទានមួយដល់សិរីទេត្ត នឹងៈចារហើយ ទើបទ្រង់ឲ្យជនទាំងពីរនេះថយខ្លួនទៅ" ។

លុះដល់និយាយរឿងនេះចប់ អារក្សនិយាយថា: "បពិត្រព្រះមហារាជ! តើជនទាំងពីរនេះ ជនណាខុសជាងគេ ។ ព្រះបាទពិករ័នត្រាស់ថា "គឺស្រីជាភរិយានោះឯង" ។ អារក្សសួរថា: ហេតុម្ដេចក៏យ៉ាងដូច្នោះ? ។ ព្រះអង្គទ្រង់មានបន្ទូលថា ទោះបីមនុស្សប្រុសអន់ថយយ៉ាងណាក៏ដោយ មនុស្សប្រុសនោះគឺគង់នៅមានសញ្ញាល្អនឹងអាក្រក់ដែរ តែឯស្រីវិញគ្មានទេ ។ ហេតុដូច្នេះ គឺស្រីហើយដែលខុសធ្ងន់ជាងគេ ។

លុះឮពាក្យអស់នេះ អារក្សក៏ដើរចេញទៅ រួចត្រឡប់ទៅព្យួរខ្លួននៅលើដើមឈើ ។ ឯស្ដេចវិញក៏ទ្រង់យាងចេញទៅដែរ ស្ដេចយាងទៅរកអារក្សនោះ ចងអារក្សដូចមុន លីលើស្មាព្រះអង្គ ហើយយាងទៅមុខទៀត ។

(មានត)

# រឿងស្នេហាជាតិ

## ៤ ឈុត

### លោក គង់-លីម និស្សិតសាលាគរុវិជ្ជា ភ្នំពេញ តែង

---

*រឿងស្នេហាជាតិនេះ វង់ល្ខោនកូនសិស្សសាលាគរុវិជ្ជា ភ្នំពេញ ដែលមានឈ្មោះ គង់-លីម ជាមេបង្ហាត់ បានលេងលើកដំបូង នៅរោងល្ខោនច្បារអំពៅ ក្នុងរាត្រីនៃថ្ងៃអាទិត្យទី ៤ កុម្ភៈ ឆ្នាំ ១៩៥១*

| | | |
|---|---|---|
| ម៉ារ៉ា | = | គង់-លីម |
| មិត្តណា | = | អៀ-គីមសាន |
| ភាណរិទ្ធ | = | ប៊ុយ-ហេង |
| ភាណនរា | = | ប៉ាំង-ម៉េងលី |
| ភាណី | = | ស្វាយ-ថន |
| មិត្តភាព | = | ម៉ាំង ម៉ារូណាល |
| ផលតារី | = | ងួន ស៊ីអ៊ិន |
| សុខា | = | កែម-សុខុម |
| វណ្ណតារា | = | ផូ-ក៉ |
| វណ្ណតារី | = | អ៊ុន-សម្បត្តិ |

រឿងល្ខោនដដែលនេះ បានលេងលើកទី ២ ពីរលើកទៀតនៅមន្ទីរ
មហោស្រព ភ្នំពេញ ក្នុងថ្ងៃទី ៨ និងទី ១០ ខែកុម្ភៈ ឆ្នាំ ១៩៥១ ។

## តួ

| | | |
|---|---|---|
| ម៉ារ៉ា | = | គ្រូបង្រៀន |
| មិត្តាណា | = | ខេមរនិស្សិត កូនប្រុសលោកម៉ារ៉ា |
| ភាណារិទ្ធិ | = | កូនសិស្សនៅវិទ្យាល័យ |
| ភាណានា | = | អនុសេនីយទោ |
| ភាណី | = | កូនសិស្សក្រសួងសុខាភិបាល |
| មិត្តភាព | = | កូនសិស្សនៅសាលាសិប្បយការ |
| ធិលនារី | = | កូនសិស្សនៅអនុវិទ្យាល័យនារី |
| សុខា | = | ស្រីមេម៉ាយមានសម្បត្តិ |
| វណ្ណតារា | = | កូនស្រីអ្នកសុខា |
| វណ្ណនារី | = | កូនស្រីអ្នកសុខា ប្អូននាងវណ្ណតារា |

## រឿងហេតុកើតឡើងនៅ ក្រុងភ្នំពេញ

## ឈុតទី ១ ឆាកទី ១

# ភាណរិទ្ធិ - មិត្តភាព - ផលនារី

### ភាណរិទ្ធិ

ទឹកទៅតូចចិត្តពន់ពេកណាស់ ខ្មាសអើយសែនខ្មាសពន់ប្រមាណ
កាលដែលគេឈ្នះចិត្តសាមាន្យ ក្លាហានស្រែកហ៊ោសប្បាយចិត្ត ! ។

### មិត្តភាព

សប្បាយមែន ! ក្នុងចិត្តរីករាយ ល្បែងទាត់បាល់ងាយតែឈ្នះពិត
ស្រែកហ៊ោឥតក្រែងតាមគំនិត នរណាចិត្តច្រើនខឹងណាស់សា ! ។

### ភាណរិទ្ធិ

ហ៊ោបញ្ឈឺចិត្ត ! សឹងធ្លាក់ថ្ងើម

### មិត្តភាព

ហ៊ោឲ្យសម្បើមតាមប្រាថ្នា ថ្ងើមបងធ្លាក់នៅកន្លែងណា
ខ្ញុំនឹងយាត្រាទៅរើសជូន ! ។

### ភាណរិទ្ធិ

កុំបាច់និយាយដុញឲ្យអញ តែកាញ់ក្នុងចិត្តឥតស្គាល់ប្អូន !

### មិត្តភាព

បើស្លាប់ខ្ញុំមួយមិនសាបសូន្យ បងប្អូនឯទៀតនឹងកើតខ្វល់ ! ។

បើបងដាល់ខ្ញុំ ចាប់ដៃស្អាត  បើបងទាត់ ខ្ញុំទាក់វិញឲ្យផ្អួល
ឈ្មោះបងប្អូនឯងព្រោះល្បែងបាល់  ដឹងដល់លោកប៉ាវាយខ្នងខ្ញុំ ។

ភាណរិទ្ធិ

នៅស្ងៀម! នៅស្ងៀម! អាចម្កួត! អាងអួតតែកាប់ចាក់ដល់ទី
អាឯងគ្មានទេធម៌សាមគ្គី  បានតែដេកស៊ីហើយឈ្លោះគ្នា ។

មិត្តភាព

នរណា? រូបបង ឬមួយខ្ញុំ  សូមប្រាប់ឲ្យចំឲ្យឆាប់ក៏
កំពុងចិត្តខ្ញុំនៅហានក្លា  រូបនរណាមួយដែលពុំគួរ? ។

ភាណរិទ្ធិ

ឯងនៅឆ្ងល់ទៀតពីរឿងហ្នឹង,

មិត្តភាព

ព្រោះតែមិនដឹងបានជាសួរ

ភាណរិទ្ធិ

គឺជារូបឯង ឆ្លើយដោយគួរ  សំនួរយ៉ាងនេះ គួរឲ្យសើច ។

មិត្តភាព

សើចទៅ សើចទៅ កុំថាចង់  ឲ្យអស់ចំណង់ អាសំណើច
បើរូបណាខុស អញមិនសើច  វាយស្អិតញើច អញគ្មានគុំ ។

ឈុតទី ១ ឆាកទី ២

# ផលនារី-ភាណរិទ្ធិ-មិត្តភាព

## ផលនារី

ទៀតហើយបងទាំងពីរឈ្លោះគ្នា! នាំឲ្យវេទនាដល់ចិត្តខ្ញុំ
តែដឹងដល់ប៉ាកើតទោសធំ ក្រៀមក្រំពល់ពេលនាំរំខាន ។

## ភាណរិទ្ធិ

គឺរូបប្អូនហើយជាចៅក្រម ជំនុំជំរះរឿងនេះបាន

## មិត្តភាព

ផលនារីកាត់ក្តីរឿងមិនក្សាន្ត! បែកបានជាធំអញខ្មាសគេ ។
ឯងសមដឹងបង! អញដឹងហើយ ចិត្តអញមិនស្បើយពីក្តាញ់ទេ
ជជែកចុះឡើងគេទំនេរ ទោសទេមកខុសអញចង្រៃ ។

## ផលនារី

សិស្សសាលាបង ខូចអនេក ដូចក្អែកបោមសាច់ឆៀតពាលថ្ងៃ
តែឃើញស្រី សិស្សបោមព្រើនព្រែក ប្រកែកពីជិនណាយគួរអនិច្ចា ។

## ភាណរិទ្ធិ

មែនពិត អញឃើញកាលតាំងតុ ឯងដើរសុំគុកគយនេត្រា
ឱតស្រីនៅក្បែរបន្ទប់យា លោកប៉ាលបមើលជាមួយអញ ។

## មិត្តភាព

បងឯងស្រីដេរ នៅដោយផ្សារ ក៏ដេរដល់ចុះលោកកើតក្នាញ់

អាខ្នោះ! អាគុក! អាគេបាញ់! ម្ដេចលាងខ្លួនវិញនៃលោកនាយ! ៗ

## ផលនារី

យី! បងភាណវិទ្ធដល់ម៉ឹង ប្អូ!

## ភាណវិទ្ធ (ទះកំភ្លៀងមិត្តភាព)

នេះគឺ រង្វាន់អញចំណាយ បើអាដឹងហើយម្ដេចនិយាយ?

អញវាយមួយដៃតាមទំនើង ៗ · (ចូល)

## មិត្តភាព

ទេព្ដាមានភ្នែកជួយចាំដាក់ ចង្រៃអប្បលក្ខណ៍កើតមានឡើង

នៅក្នុងក្រុមញាតិអាប់មិនចើង ដូចដាចម្បើងក្នុងគង្គា ៗ

## ផលនារី (យកកន្សែង បោសទោ - អាវឲ្យបង)

ធ្វើម្ដេចខ្លួនខ្ញុំនឹងជួយបាន ចិត្តគាត់ក្លាហានក្នុងគ្រួសារ

វាយតែធ្នាំងឯងឲ្យប្រេះឆា អាប់យសសក្ដាគេមើលងាយ ៗ (ចូល)

## មិត្តភាព

ឱ! ផលនារីនាងក្មេងតែខ្លួន តែចិត្តជាប់ដួនមិនវាយមាយ

ម៉េះសមក្នុងទ្រូងតឹងស្ទើរក្ដាយ ហាមាត់និយាយទៀតពុំបាន ៗ

ការសងសឹកជាការរួចខ្លួន សេចក្ដីគុំគួនព្រួយក្នុងប្រាណ
នាងធ្វើពេលណាទើបស្រាកស្រាន្ត ហើយបានពេញចិត្តតែនៅភ័យ ៗ
ការណរិទ្ធិ - មិត្តភាពជាប់ឈាមសាច់ កាលណាកាត់ដាច់លែងអាល័យ
បើនឹងសងសឹក ឱម្ចាស់ថ្លៃ ! ខ្លួនខ្ញុំចង្រៃដល់មេបា ៗ
បើនាងប្អូនខ្ញុំលាក់កេរ្តិ៍ជិត ពីបងការណរិទ្ធក់យខ្ញុំណា
មិនឲ្យដឹងដល់វណ្ណ៍តាក សមខ្ញុំជ្រះថ្លាក្នុងចិត្តក្រៃ ៗ
បើរឿងនេះលេចឮសព្ទសាយ កេរ្តិ៍ឈ្មោះអន្តរាយគ្មានដំឡៃ
ទាំងក្រុមគ្រួសារក៏អន់ថ្លៃ អ្នកផងទីទៃហ៊ានមើលងាយ ៗ

## ឈុតទី ១ ឆាកទី ៣

## មត្តាណា - ភាណី

### មិត្តាណា

បងប្អូនសុទ្ធសឹងតែអ្នកបេះ ដម្រេះមានសព្វតែរៀងខ្លួន
ប៉ុន្តែបុកពាធ្វើមិនសួន មិនធួនសមជាតិជាអ្នកថ្លៃ ៗ
មេបាចំណាយប្រាក់ឲ្យរៀន ចំណេះរៀនជាដំឡៃ
មិនខំធ្វើការយកកំរៃ សងថ្លៃចំណាយដូសលោកវិញ ៗ
គិតតែឈ្មោះគ្នាដណ្ដើមធំ នេះហៅជាចំគ្មានចំណេញ
ញាតិសាលោហិតនៅពាសពេញ ទន្ទេញទន្ទឹងចិត្តរំជួល ៗ

អ្នកប្រាជ្ញនឹងមករៀបចំញាតិ ធ្វើឲ្យបាកឃ្មាតពីទុក្ខព្រួយ
សព្វថ្ងៃនៅមានតែផ្លូវមួយ គឺ . . . . . . . .

## ភាណី

បាក់ថ្មាំការពារកេតាឆ្កួត ! ឆ្កួតស្រែ ! ឆ្កួតស្រា !
អាកៀនកញ្ឆា ! ស្រវឹងកុណប្រស័ក្ត !
ក្មួចបងក្មួចប្អូន ក្មួច . . .

## មិត្តាណា

ខ្លួនជាឯងឆ្កួតដែរ

## ភាណី

ឆ្កួតស៊ីតាប៉ៃលាយទឹកត្នោតជូរ ឆ្កួតផឹកទឹកប៉ោតក្រមសាប៊ូ
ឆ្កួតផឹកទឹកត្នោតជូរ ក្រមកង់ឡាន ឆ្កួត . . . . . . . .

## មិត្តាណា (យកដៃខ្ទប់មាត់ភាណី)

និយាយតិចៗ កុំឲ្យខ្លាំង មិនមែនបាកំងស្រវឹងទេ
ឡូឡាខ្លាំងពេកខ្លាចប៉ាដេរ ផ្ទះយើងហួសគេព្វតែមាត់ ៗ

## ភាណី

ឡូឡាខ្ញុំស្រែកប្អូនណា (ខ្លាំង) បងមិត្តាណាឯងម្តេចមិនឃាត់

### មិត្តាណា

ពល់ពេលវេលាតែងតូមាត់ ប្រាកដតត់គិតឲ្យវែងឆ្ងាយ ៗ
មិនមែនតែឯងទេហ្វងហ្វាង កាណារិទ្ធិចិត្តផ្ទាំងគ្មានសប្បាយ
និយាយកាលណាមុខមិនស្រាយ ចំពោះមុខក្រោយខ្ញុំស្អប់មុខ ! ៗ

### ភាណី

កាណារិទ្ធិ ! ចិត្តគេធំអស្ចារ្យ គេចង់ត្រួតត្រាលោកឪពុក
និយាយកាលណាបណ្ដាលទុក្ខ ប៉ុន្តែឪពុកពប់ពេញទី ៗ
អាចោរ ! ស៊ីបាយហើយបោកផ្ទាំង

### មិត្តាណា

ឯងថាត្រូវម៉ាំង ! ហើយកាណី

### ភាណី

តែបាយឆ្អែតហើយដើរកាល់ញី ថ្ងៃមុនឃើញពីរនៅមុខកាំង ៗ

### មិត្តាណា

តំនិតខិលខូចនាំទាបថោក ឲ្យស្រីៗ បោកខ្លួនក្បាត់ក្បាំង
ដល់ផ្ទះកាលណាផ្ដើមតតាំង ប្រកួតប្រណាំងរករឿងឈ្លោះ ៗ
មិនអាសូរដល់ទ្រង់អ្នកហាត់ លំបាកខំអត់ជាបត្រដួស
តែឃើញកាលណាយើងធ្វើហួស ចំពោះខ្លួនលោកព្រួយយ៉ាងណា ៗ

ភាណី

អាណិតបាណាស់ណាបងអើយ! ម៉េះហើយលោកកើតទុក្ខខ្លាំងក្លា

មិត្តាណា

អាណិតអី? បើឯងស្រែកឡូឡា

ភាណី

ពីថ្ងៃនេះណា ខ្ញុំលែងស្បិត ។ ខ្ញុំនៅឲ្យស្ងៀមដូចអ្នកតា
បំរើលោកបាឲ្យអស់ចិត្ត!

មិត្តាណា

សាធុ! សាធុ! បងអរពិត ប្អូនប្រែគំនិតល្អត្របះ ។

ភាណី

ខ្ញុំប្រែគំនិត ចិត្តជាថ្មី! រក្សាសេចក្តីសុខក្នុងផ្ទះ
ថែទាំឥម្ចីឲ្យស្រឡះ ថែញាតិក្នុងផ្ទះឲ្យសុខសាន្ត ។

មិត្តាណា

សេចក្តីសង្ឃឹមញញឹមទុក ថានឹងបានសុខគ្រប់អង្គប្រាណ
បងប្អូនជិតឆ្ងាយញាតិសន្តាន ដោយសារប្អូនបានធ្វើសោភា ។

ភាណី

ធ្វើចំពោះជាតិគ្មានរើសមុខ ថែទាំសុខទុក្ខនៃរូបា
ប្រុស - ស្រីទាំងឡាយជាតិខេមរា ខ្ញុំការពារពេកគ្មានរើ ។

ធ្វើការដោយកាយ   ធំនៅចិត្ត   គំនិតគិតឃើញហើយត្រូវធ្វើ
បំពេញករណីយឲ្យប្រសើរ   បំពេញដំណើរយានសម័យ ។
កម្ពុជាបែរមុខទៅគ្រប់ទិស   ត្រូវខំធ្វើពិសកុំដកដៃ
ឲ្យស្រុកផងយើងជឿនរាល់ថ្ងៃ   ឲ្យដូចសម័យនគរវត្ត ! ។

(ភាណីរត់ចូលក្នុង ដោយឃើញមិត្តភាពកាន់កាំបិត)

(មានត)

## ពិធីបុណ្យជំនួនព្រាត់

*នៅវត្តដើមអម្ពិល ខេត្តពោធិ៍សាត់ (យៀកណាម)*

## ព្រះមហាឈិត កំលីន

សិស្សសាលាបាលីជាន់ខ្ពស់ ថ្នាក់ទី-៤ (ក) វត្តឧណ្ណាលោម ក្រុងភ្នំពេញ រៀបរៀង

(តចប់)

---

### សុន្ទរកថា

## របស់ព្រះមហា គឹម-យួន អាចារ្យ វត្តដើមអម្ពិល

## អ្នកបណ្ឌិត ហាង-កៀង ស្ងួតជំនួស

*ព្រះតេជព្រះគុណ !*

*ព្រះករុណា ទាំងឡាយ !*

*លោកអ្នកសប្បុរសទាំងអស់គ្នា !*

*ឱកាសនេះជាពេលប្រកបដោយមង្គលនក្ខត្តឫក្សល្អ ជាអភិលក្ខិតសម័យដ៏ប្រសើរ នៃបុណ្យរបស់យើងពលគ្នា ។ ហេតុនេះ ខ្ញុំព្រះករុណា អាត្មាភាព សូមឱកាសបន្តិចនឹងថ្លែងអំពីបុព្វហេតុបុណ្យនេះប្រគេនជូនជាដំណឹង ។ បុណ្យនេះមានមូលហេតុដែលនាំឲ្យកើតឡើង ដោយខ្ញុំព្រះករុណា អាត្មាភាពមានចិត្តទឹកក្នុកមមៃយ៉ាងមមាញឹកថា ចង់ប្រតិស្ឋានគោលបំណង ៣ យ៉ាងឲ្យសម្រេច គឺ :*

១ - ទ្រព្យសម្បត្តិគ្រប់យ៉ាងក្នុងលោក ទោះល្អអាក្រក់ មានតម្លៃឥតតម្លៃ ច្រើន តិច មានវិញ្ញាណ ឥតវិញ្ញាណ កាលណាពួកកាយធុះធ្លាយ វិញ្ញាណក្ខន្ធអណ្តែតបាត់ទៅហើយ ឥតមានអ្នកណាម្នាក់អាចវេចខ្ចប់ ស្ពាយយកទៅតាមផងបានឡើយ ។

២ - ជីវិតមនុស្សសុទ្ធសឹងធ្លាក់ទៅក្នុងអំណាចនៃសេចក្តីស្លាប់ បើរស់នៅមិនបានកសាងបុណ្យទានអ្វីបន្តិចបន្តួច ដើម្បីជាសុភារម្មណ៍ទេ, ឈ្មោះថាជាមនុស្សខាតធំ ព្រោះកើតមកពុំបានបំពេញកុសលជាទីពឹងក្នុងពេលដែលខ្លួនត្រូវលះលោកនេះ ទៅកាន់លោកខាងមុខ ។ មានតែកុសលធម៌ដែលយើងបានកសាងទុកនេះហើយ ដែលជាមិត្តក័ក្តិគួរកនជូនដំណើរយើងទៅកាន់បរលោកបាន ។

៣ - អំពើជាកុសលដទៃ ៗ មានបុណ្យពុទ្ធាភិសេករូបបដិមាករ, សាងព្រះវិហារ, សាងកុដិ, សាលា, សាងថ្នល់, ព្រះចេតិយជាដើមអស់លោកអ្នកជាសប្បុរសទាំងអស់គ្នា ធ្លាប់បានធ្វើខ្លះមកហើយ នៅសល់តែសាលាបរិយត្តិបឋមវិជ្ជា និងអគ្គិកត្តសាលាប៉ុណ្ណោះទេ ដែលមិនធ្លាប់បានធ្វើ ។ សម័យនេះ អាត្មាភាពនិងលោកអ្នកទាំងឡាយមានអធ្យាស្រ័យស្របគ្នាតែមួយថា នឹងកសាងបុញ្ញនិធានកិច្ចនេះឡើងត្រូវបំណងនោះក៏បានសំរេចហើយ ។

ឯធម៌ជាសត្រូវនៃគោលបំណងនេះគឺមច្ឆរិយៈ១ នេះបានដល់សេចក្តីកំណាញ់កាញ់សម្បត្តិទុក ជាកិលេសនាំឲ្យសៅហ្មងចិត្ត ដឹកនាំឲ្យនាំ

សត្វឲ្យលះធនធានធ្វើទៅជាទានមិនកើត ព្រោះខ្លាចអស់លស់ទ្រព្យសម្បត្តិរបស់ខ្លួន ម្ល៉ោះហើយក៏ខំបរិហារការពារធនទុក ដូចចាបស្រែកការពារទ្រនំមិនឲ្យសត្វដទៃទំផងបានដូច្នោះឯង ។ មច្ឆរិយធម៌នេះ ឈ្មោះថាយើងបានឈ្នះ ព្រោះបានបរិច្ចាគលះធនធាន ធ្វើទៅជាទានហើយ ។

សមដូចសុភាសិតក្នុងលោកនីតិថា :–

ទានំ សិនេហភេសជ្ជំ មច្ឆេរំ ទោសនោសធំ
ទានំ យសស្ស ភេសជ្ជំ មច្ឆេរំ កប្បនោសធំ

ទានជាថ្នាំនាំកើតក្តីស្នេហា កំណាញ់ជាឱសថនៃទោសទុក្ខ
ទានជាថ្នាំយសស័ក្តិចំរើនសុខ កំណាញ់ទុកជាថ្នាំនាំកំព្រា ។

មួយទៀតសមដូចពុទ្ធភាសិតថា :–

ទ្រព្យសប្បុរសទោះតិចតួច បានជាប្រយោជន៍ជននានា
ដូចទឹកអណ្តូងរសសាបថ្លា អស់មហាជនផងដងអាស្រ័យ ។
ទ្រព្យអសប្បុរសទោះមានច្រើន ពុំបានចំរើនអ្នកដទៃ
ដូចទឹកសមុទ្រមានរសប្រៃ មនុស្សផងអាស្រ័យផឹកពុំបាន ។

រតនត្តយតេជេន ដោយប្រជុំបីនៃព្រះត្រៃរ័ត្ន សូមទេវតាទាំងមួយម៉ឺនលោកធាតុ ពិភ័ក្តិរក្សាព្រះតេជព្រះគុណ, ព្រះករុណាទាំងឡាយ, លោកអ្នកសប្បុរសទាំងអស់គ្នា បានប្រកបដោយចតុព្វិធពរគឺ: អាយុ វណ្ណ សុខ: ពល: បរិបូណ៌ដោយសតិប្បញ្ញាបរិហារជាបុរសស្រ្តីទៅហោង ។

# សុន្ទរកថា

## របស់ព្រះមហាឧត្តមវិជ្ជា ឈីវ-កែម អាចារ្យ វត្តដើមអម្ពិល

សូមពិតពុទ្ធដីកា ព្រះតេជព្រះគុណ !

ព្រះករុណា ទាំងឡាយ !

អស់លោកសាធុសប្បុរស ជាពុទ្ធបរិស័ទទាំងអស់គ្នា

សូមទានជ្រាប និង សូមជ្រាប ។

វត្តដើមអម្ពិលនេះ បានឧប្បត្តិឡើងតាំងពីឆ្នាំណាមកទល់នឹងបច្ចុប្បន្ននេះ ហើយមានសភាពយ៉ាងណា មានសេចក្តីប្រព្រឹត្តមកយ៉ាងណា ព្រះតេជព្រះគុណ ព្រះករុណាទាំងឡាយ អស់លោកសាធុសប្បុរសទាំងអស់គ្នា សឹងបានជ្រាបសព្វគ្រប់ហើយ ។

ដល់ទីបំផុត ឧបាសកឧបាសិកាចំណុះជើងវត្តទាំងឡាយ អ្នកប្រាថ្នានូវសេចក្តីចំរើនរុងរឿងដល់វត្ត, បានព្រមព្រៀងគ្នាទុកដាក់វត្តនេះ ឲ្យនៅក្រោមអធិបតេយ្យនៃព្រះតេជព្រះគុណទាំង ៣ ព្រះអង្គគឺ ព្រះតេជព្រះគុណ ឡឹម-យ៉ុក, ព្រះតេជព្រះគុណ សឺន-ឧត្តម, ព្រះតេជព្រះគុណ គីម-ឃួន, ដោយហេតុតែមានព្រទ័យដ៏បវរវិសុទ្ធិ ប្រកបដោយសេចក្តីមេត្តាករុណា និងបដ្ឋនាការដ៏បរិសុទ្ធក្នុងការជួយទំនុកបំរុងផ្សេងៗ, ដើម្បីឲ្យវត្តនេះមានដំហានឈានទៅកាន់សេចក្តីចំរើនរុងរឿង, សមជាវត្តគួររមទីស្ដាយនទនឹងជ្រះថ្លា ដល់បណ្ដាជនអ្នកត្រូវការ ដោយបុញ្ញា-

ហេតុ, របស់ព្រះតេជព្រះគុណទាំង ៣ ព្រះអង្គ, ហើយបានអនុញ្ញាត ឲ្យភិក្ខុសាមណេរ មកគង់នៅក្នុងវត្តនេះ ថែមទាំងបាននិមន្តធម្មាចារ្យ ដែលប៉ិនប្រសប់ខាងវៃក្នុងវិធីបង្ហាត់បង្រៀនធម្មវិន័យផ្សេងៗ មកធ្វើជាអាចារ្យបង្រៀន ដោយហេតុតែព្រះទ័យយល់ឃើញថា: "បណ្ដាប្រទេសជាតិនានា ក្នុងលោកសន្និវាសនេះដែលនឹងឈានជើងលឿនទៅកាន់ភាពជាអារ្យប្រទេស ឬ អារ្យជាតិទៅបាននោះ, លុះតែរាជរដ្ឋាភិបាលរបស់ប្រទេសនោះៗ រំប្រឹងប្រែងរកកុសលោបាយ វិធីបណ្ដុះបណ្ដាលការសិក្សាដល់ប្រជាជាតិខ្លួនទៅក្នុងប្រទេសនោះៗ ឲ្យបានគ្រប់គ្រាន់ពេញលេញបរិបូណ៌ឡើង" ។ ចំណែកខាងព្រះពុទ្ធសាសនាក៏ដូចគ្នាដែរ ដែលនឹងចំរើនរុងរឿងថ្កុំថ្កើងទៅបាន, លុះតែអ្នកដែលកាន់ពុទ្ធសាសនា បានទទួលការសិក្សារៀនសូត្រប៉ែកខាងបរិយត្តិធម៌ ដឹងខុសត្រូវជ្រៅរាក់ខ្ពស់ទាប ក្នុងព្រះពុទ្ធសាសនាដោយពេញលេញ ព្រះពុទ្ធសាសនាក៏នឹងដល់នូវការៈនៃសេចក្ដីប្រសើរជាអារ្យសាសនា ។

សេចក្ដីពិតនោះ ព្រះពុទ្ធសាសនាជាអារ្យសាសនាស្រាប់ហើយ, គ្រាន់តែឲ្យអ្នកកាន់គ្រប់ៗ គ្នា ខំសិក្សារៀនសូត្រនឹងប្រតិបត្តិធ្វើខ្លួនឲ្យទៅជាអារ្យៈប៉ុណ្ណោះ ក៏បានឈ្មោះថា ជាអ្នកជួយលើកដំកើងព្រះពុទ្ធ-សាសនា ។ ដោយសារព្រះទ័យព្រះតេជព្រះគុណទាំង ៣ ព្រះអង្គ យល់ឃើញដូច្នេះ បានជាខំយកព្រះទ័យទុកដាក់ដឹកនាំភិក្ខុ សាមណេរ

ឧបាសកនិងឧបាសិកា ដែលនៅក្រោមម្លប់បារមីឲ្យចំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការសិក្សារៀនសូត្រ សមភាពជាបិតាសង្ឃទាំង ៣ ព្រះអង្គក្នុងទីនេះ ។

ក្នុងឆ្នាំថ្មីដែលជាឆ្នាំសុខនក្ខត្តឫក្សល្អ ព្រះតេជព្រះគុណទាំង ៣ ព្រះអង្គនេះ មានវត្តបំណងឲ្យភិក្ខុ-សាមណេរក្នុងវត្តអម្ពិលនេះបានទទួលការសិក្សារៀនសូត្រ ព្រះធម្មវិន័យបរិយត្តិធម៌ ដែលជាបេះដូងរបស់ព្រះពុទ្ធសាសនា ទើបបានជាខ្ញុំព្រះករុណា អាត្មាភាពមកបង្ហាត់បង្រៀនជាគ្រូដំបូង ។ ខ្ញុំព្រះករុណាអាត្មាភាព, ក៏ខំប្រឹងប្រែងពេញទំហឹងក្នុងការបង្ហាត់បង្រៀនជាមួយនឹងព្រះតេជព្រះគុណព្រះអាចារ្យ គឹម-យូន ដើម្បីឲ្យសម្រេចបដូចបំណងនៃព្រះតេជព្រះគុណទាំង ៣ អង្គនេះ ។ ខ្ញុំព្រះករុណាអាត្មាភាព បានទទួលសេចក្ដីទុកបំរុងអំពីសំណាក់ព្រះតេជព្រះគុណជាចៅអធិការ នឹងព្រះតេជព្រះគុណជាវិបស្សនាចារ្យវត្តនេះ ។

ឧបការគុណនេះ ខ្ញុំព្រះករុណាកត់សំគាល់ទុក មិនអាចនឹងលុបបាត់បង់ឬភ្លេចភ្លាំងទៅបានឡើយ ។ ខ្ញុំព្រះករុណាអាត្មាភាពយល់ថា វត្តនេះនឹងឋិតថេរយឺនយូរនៅក្នុងវង់នៃសេចក្ដីចំរើនតទៅ ព្រមអនាគតសម័យបាននោះ ក៏ដោយសារជ្រកក្រោមម្លប់ នៃសេចក្ដីទុកបំរុងយ៉ាងប្រពៃល្អ របស់ព្រះតេជព្រះគុណទាំង ៣ ព្រះអង្គនេះ ។

ក្នុងទីបំផុតនៃសុន្ទរកថានេះ ខ្ញុំព្រះករុណាអាត្មាភាព, សូមព្រះតេជព្រះគុណទាំង ៣ ព្រះអង្គ មេត្តាប្រោសប្រទានជម្បូនានដល់បណ្ដាភិក្ខុ - សាមណេរ - ឧបាសក - ឧបាសិកា ដើម្បីឲ្យបានប្រកបដោយជោគជ័យ សិរីសួស្ដី ហើយនឹងសូមព្រះសង្ឃទាំងអស់អង្គផ្ចង់មេត្តាចិត្តសូត្រ "ជយន្តោ" ដើម្បីជាជយមង្គលនៃសាលារៀនព្រះបរិយត្តិធម្មវិន័យក្នុងវត្តដើមអម្ពិលនេះតទៅ ។

---

# សេចក្តីបញ្ជាក់តាមការណ៍ពិត

អស់លោកអ្នកយល់ស្រាប់ហើយថា៖ សៀវភៅកម្ពុជសុរិយារបស់ពុទ្ធសាសនបណ្ឌិត្យ ជាទស្សនាវដ្តីមួយផ្សាយចេញរាល់ខែ សម្រាប់ពង្រីកពុទ្ធសាសនានិងអក្សរសាស្ត្រ ។ ការផ្សាយចេញនូវពុទ្ធសាសនានិងអក្សរសាស្ត្រនេះ គឺជាគោលការរបស់ពុទ្ធសាសនបណ្ឌិត្យ ព្រោះពុទ្ធសាសនា ជាអត្ថបទផ្សាយនូវផ្លូវធម៌, អក្សរសាស្ត្រ ជាអត្ថបទផ្សាយនូវផ្លូវលោក ។ ផ្លូវធម៌និងផ្លូវលោក ត្រូវតែមានជាគូគ្នាជាប លះបោលគ្នាពុំបាន ដូចព្រះអាទិត្យនិងព្រះចន្ទ្រ ដែលត្រូវតែជាគូគ្នាបំភ្លឺលោក ។

ហេតុនេះ អស់លោក-អ្នក បងប្អូនរួមជាតិ ដែលជាអ្នកអានទស្សនាវដ្តីកម្ពុជសុរិយា សូមយល់ថា ក្នុងទស្សនាវដ្តីនេះ និងផ្សាយចេញតែសាសនាម្យ៉ាង ឬអក្សរសាស្ត្រម្យ៉ាង នោះឃើញថាពុំកើត ត្រូវតែឲ្យមានទាំងពីរ ទើបសមរម្យទៅតាមកាលៈទេសៈ ។

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ